FTB

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា







# របាយការណ៍ប្រចាំឆ្នាំ

# ២០០៨

# មាតិកា


| | | ទំព័រ |
|---|---|---|
| ១ ទស្សនៈទូទៅនៃអាជីវកម្ម | ព័ត៌មានទូទៅរបស់ធនាគារ | ១ |
| | បេសកកម្ម និងចក្ខុវិស័យ | ២ |
| | ទិដ្ឋភាពទូទៅរបស់ធនាគារ | ៣ |
| | អង្គការលេខរបស់ធនាគារ | ៣ |
| | របាយការណ៍ហិរញ្ញវត្ថុសង្ខេបរយៈពេល៤ឆ្នាំ | ៤ |
| | លទ្ធផលអនុវត្តអាជីវកម្មក្នុងឆ្នាំ | ៥ |
| | សាររបស់លោកប្រធានក្រុមប្រឹក្សាភិបាល | ៦ |
| | សាររបស់អគ្គនាយក | ៧ |
| ២ អភិបាលកិច្ច | ក្រុមប្រឹក្សាភិបាល | ៨ |
| | គណៈគ្រប់គ្រងប្រតិបត្តិ | ៨ |
| | ប្រវត្តិរូបរបស់គណៈគ្រប់គ្រង | ១០ |
| | របាយការណ៍ក្រុមប្រឹក្សាភិបាល | ១២ |
| ៣ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | របាយការណ៍គណៈគ្រប់គ្រងប្រតិបត្តិ | ១៥ |
| | របាយការណ៍របស់សវនករឯករាជ្យ | ១៧ |
| | របាយការណ៍លទ្ធផល | ១៨ |
| | តារាងតុល្យការ | ១៩ |
| | របាយការណ៍ស្តីពីការប្រែប្រួលនៅក្នុងមូលនិធិភាគទុនិក | ២០ |
| | របាយការណ៍លំហូរសាច់ប្រាក់ | ២១ |
| | កំណត់សំគាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ | ២២ |
| | ឧបសម្ព័ន្ធ១: កំណត់សំគាល់ចំពោះការអនុវត្តន៏តាមប្រកាសរបស់ធនាគារជាតិ | ៤២ |
| | តារាង ១ : អនុបាតសាច់ប្រាក់ងាយស្រួល | ៤៣ |
| | តារាង ២ : មូលនិធិផ្ទាល់សុទ្ធ | ៤៤ |
| | តារាង ៣ : អនុបាតសាធនភាព | ៤៥ |
| | ការគណនាអនុបាតផ្សេងៗ | ៤៦ |
| ៤ ភាគីទំនាក់ទំនងបរទេស | សេចក្តីណែនាំស្តង់ដារនៃការទូទាត់ | ៥១ |



# ព័ត៌មានទូទៅរបស់ធនាគារ

| | |
|---|---|
| **ទ្រង់ទ្រាយគតិយុត្ត :** | ធនាគាររដ្ឋចំរុះឯកជន |
| **ទីស្នាក់ការកណ្តាល :** | ស្ថិតនៅអាគារលេខ៣ វុក្ខវិថីក្រមួនស សង្កាត់ផ្សារថ្មី១ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។<br>ប្រអប់សំបុត្រ 1550 PNH, Cambodia<br>ទូរស័ព្ទ : +855 (0)23 724 466 / 722 466 / 725 266<br>ទូរសារ : +855 (0)23 426 108 / 426 410<br>អ៊ីមែល : ftb@camnet.com.kh<br>www.ftbbank.com<br>SWIFT: FTCCKHPP |
| **ដើមទុនចុះបញ្ជី :** | ៥០,០០០,០០០,០០០រៀល |
| **អាជ្ញាប័ណ្ណអាជីវកម្មលើកដំបូង :** | លេខ១៦ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ |
| **វិសោធនកម្មលក្ខន្តិកៈ :** | វិសោធនកម្មលក្ខន្តិកៈនៅធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៦ |
| **ចុះបញ្ជីពាណិជ្ជកម្មសារជាថ្មី :** | លេខ Co ៨៨៣៥ ០៦M ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០០៦ |



# បេសកកម្ម

ដើម្បីប្រែក្លាយជាធនាគារដ៏ល្អមួយនៅកម្ពុជា នៅក្នុងជំនឿរបស់អតិថិជន កិត្តិសេវាកម្ម និងកិត្តិផលិតផល ។ យើងនឹងធ្វើអោយសំរេចនូវបេសកកម្មខាងលើនេះ ដោយផ្តល់នូវសេវាកម្មថ្នាក់លេខមួយ និងផលិតផលហិរញ្ញវត្ថុយ៉ាងសមរម្យ និងប្រកបដោយការច្នៃប្រឌិត ដោយមិនត្រឹមតែបង្កើតអោយមានឡើងនោះទេ គឺធ្វើអោយមានតំលៃជាអតិបរមាសំរាប់អតិថិជន និងភាគទុនិករបស់យើង ។

ក្នុងនាមជាអង្គភាពមួយ យើងប្រឹងប្រែងអោយអស់លទ្ធភាព ដើម្បីជោគជ័យ ភាពល្អបំផុត និងប្រកបដោយស្តង់ដារខ្ពស់បំផុត សម្រាប់អ្វីដែលយើងធ្វើដោយជ្រើសរើសបុគ្គលិកដែលមានគុណភាពកំពូល បង្កើតកន្លែងធ្វើការដែលប្រកបដោយទិន្នផលខ្ពស់ ផ្តល់បរិដ្ឋានរៀនសូត្រប្រកបដោយសុខភាព និងទទួលស្គាល់ ព្រមទាំងផ្តល់រង្វាន់ដល់បុគ្គលិកយើង និងកសាងក្រុមការងារមួយមានសមត្ថភាព និងត្រៀមខ្លួនដឹកនាំធនាគារឆ្ពោះទៅកាន់សម័យកាលថ្មីប្រកបដោយជោគជ័យ ។



# ចក្ខុវិស័យ

ដើម្បីប្រែក្លាយជាធនាគារដ៏ល្អមួយនៅកម្ពុជា និងទទួលស្គាល់ពីអតិថិជនដោយ :

- ផ្តល់ជូនភាគទុនិក នូវផលចំណេញលើការវិនិយោគ យ៉ាងសមរម្យ និងយូរអង្វែង
- ជានិយោជកដ៏ល្អបំផុត ដោយឈរលើមូលដ្ឋាន ប្រាក់បៀវត្ស លក្ខខណ្ឌការងារ និង ឱកាសនៃការអភិវឌ្ឍន៍ការងារ
- ផ្តល់នូវតំលៃការងារល្អ ផលិតផលដ៏ល្អបំផុត សុវត្ថិភាព និងកិត្តិសេវាកម្មខ្ពស់សំរាប់អតិថិជនរបស់យើង
- ចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាតាមរយៈការអនុវត្តន៍យុទ្ធសាស្ត្រវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។

FTB
ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

## ទិដ្ឋភាពទូទៅរបស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជាបានបង្កើតឡើងនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ដោយអនុក្រិត្យលេខ១២១៣ ក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ក្នុងគោលដៅ :

- ធ្វើប្រតិបត្តិការ និងផ្តល់សេវាកម្មធនាគារ
- គ្រប់គ្រងប្រតិបត្តិការទិញដូររូបិយប័ណ្ណ
- ប្រតិបត្តិការទូទាត់អន្តរជាតិ
- ផ្តល់ឥណទានគ្រប់ប្រភេទ
- រួមចំណែកការពាររូបិយវត្ថុជាតិ និងទ្រព្យសម្បត្តិរដ្ឋ
- ពង្រឹងសេដ្ឋកិច្ច និងទំនាក់ទំនងវប្បធម៌ខាងក្នុង និងខាងក្រៅប្រទេស
- ធ្វើប្រតិបត្តិការក្នុងរូបភាពជានីតិបុគ្គលដោយឡែក ពីរដ្ឋាភិបាល

ចាប់ពីថ្ងៃប្រវត្តិសាស្ត្រ៧មករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃរំដោះ ដល់ឆ្នាំ១៩៩៩ ធនាគារបានប្រឹងប្រែងដើម្បីធ្វើឱ្យសំរេចគោលដៅខាងលើនេះ ដោយធ្វើប្រតិបត្តិការរបស់ខ្លួនក្នុងនាមជានាយកដ្ឋានមួយរបស់ធនាគារជាតិនៃកម្ពុជា ។ ដោយមានរៀបចំប្រព័ន្ធអាជីវកម្ម និងនីតិវិធីសមស្រប ធនាគារបានដើរតួនាទីមួយយ៉ាងសកម្ម ក្នុងទីផ្សារក្នុងស្រុក និងក្រៅប្រទេស ដែលទទួលបានជាលទ្ធផលមកវិញ គឺការបានចូលរួមចំណែកក្នុងការស្តារសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ។ មិនយូរប៉ុន្មាន ធនាគារក៏បានទទួលទំនុកចិត្តអំពីអតិថិជន និងបានកសាងសមត្ថភាពបច្ចេកទេសចាំបាច់សំរាប់ធ្វើអាជីវកម្មបានចំណេញ ។

ចាប់ពីឆ្នាំ១៩៩៩មក ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ច ដោយផ្តល់ឱកាសអោយធនាគារជាតិ នៃកម្ពុជា ធ្វើការផ្តោតអារម្មណ៍លើតួនាទីរបស់ខ្លួនកាន់តែខ្លាំងក្លាឡើង ក្នុងនាមជាធនាគារកណ្តាល និងជាអាជ្ញាធររូបិយវត្ថុជាតិ ការធ្វើឯកជនភាវូបនីយកម្មត្រូវបានកំណត់ជាគន្លឹះសំខាន់សម្រាប់កែទំរង់ធនាគារ ។ ដំណើរការឯកជនភាវូបនីយកម្មនេះ ត្រូវបានរៀបចំឡើង និងអនុវត្តតាមកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០ ធនាគារជាតិ នៃកម្ពុជា បានបន្តការកែទំរង់របស់ខ្លួនអោយកាន់តែសកម្មឡើងថែមទៀត ដោយបានផ្ទេរអត្តសញ្ញាណកម្មអចិន្ត្រៃយ៍របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ទៅជាធនាគារពាណិជ្ជរបស់រដ្ឋ មានចរិតជាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ។ គោលដៅនៃការកែទំរង់នេះ គឺដើម្បីឱ្យធនាគារធ្វើអាជីវកម្មស្វយ័តស្មើមុខជាមួយធនាគារពាណិជ្ជដ៏ទៃទៀត ដោយផ្អែកលើច្បាប់ស្តីពី "គ្រឹះស្ថាន ធនាគារ និង ហិរញ្ញវត្ថុ" ។

នៅថ្ងៃ ទី០១ ខែសីហា ឆ្នាំ២០០២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកាន់កាប់ភាគហ៊ុនចំនួន៨០% របស់ធនាគារពាណិជ្ជកម្ម ក្រៅប្រទេស នៃកម្ពុជា ហើយនៅសល់ចំនួន២០%ទៀត ត្រូវបានកាន់កាប់ដោយធនាគារជាតិ នៃកម្ពុជា ។

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ ធនាគារបានប្តូរពីរូបភាពគតិយុត្តជាធនាគាររដ្ឋមកជាធនាគាររដ្ឋចំរុះឯកជន ។ ម្ចាស់កម្មសិទ្ធិថ្មី គឺធនាគារកាណាឌីយ៉ាភីអិលស៊ី មាន៤៦% ក្រុមហ៊ុនអាយអិនជីហូលឌីងខូអិលធីឌី ៤៤% និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១០% នៃដើមទុនសរុប ។
ជាលទ្ធផលនៃការផ្លាស់ប្តូរនេះ បច្ចុប្បន្នក្រុមប្រឹក្សាភិបាលធនាគារ មានសមាសភាព៦រូប ។ ប្រធានក្រុមប្រឹក្សាភិបាលមកពីធនាគារកាណាឌីយ៉ាភីអិលស៊ី និងអនុប្រធានមកពីក្រុមហ៊ុនអាយអិនជីហូលឌីង ខូអិលធីឌី ។

## អង្គការលេខរបស់ធនាគារ



# របាយការណ៍ហិរញ្ញវត្ថុសង្ខេបរយៈពេល៤ឆ្នាំ

## តារាងតុល្យការសង្ខេប ( ដុល្លារអាមេរិក)

| | 2005 | 2004 | 2003 | 2002 |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | ១៦៣,៥០៤,៦៩៨ | ១៥៩,៨៤៧,០៩០ | ១៥១,១៤១,៩៥៩ | ១៥២,៩៦៥,១៧៦ |
| ការផ្តល់ឥណទាន( សុទ្ធ) | ៣០,៨៤៩,៩៤៥ | ៣២,៦៤៧,៧៨៣ | ៣១,២៨៣,៧៨៩ | ២៥,២៩៦,៧៧៣ |
| ទ្រព្យសកម្មផ្សេងៗ | ១៣២,៦៥៤,៧៥៣ | ១២៧,១៩៩,៣០៧ | ១១៩,៨៥៨,១៧០ | ១២៧,៦៦៨,៤០៣ |
| ទ្រព្យអកម្មសរុប | ១៤៤,៧៣៦,៦៩៨ | ១៤១,៣៨០,០៩៩ | ១៣៣,៣១៣,១៥៦ | ១៣៤,៤៤៧,៨១០ |
| ប្រាក់បញ្ញើអតិថិជន | ១៤៣,៦២៨,២៥៩ | ១៤០,២០៤,០៣៨ | ១៣១,៨៦២,៧៥៤ | ១៣២,៦១២,៨០៧ |
| ទ្រព្យអកម្មផ្សេងៗ | ១,១០៨,៤៣៩ | ១,១៧៦,០៦១ | ១,៤៥០,៤០២ | ១,៨៣៥,០០៣ |
| ដើមទុនចុះបញ្ជី | ១២,១៥៩,៥៣៣ | ១២,៤១៦,១៩១ | ១២,៥៧៥,៤៥៣ | ១២,៧២២,៦៤៦ |
| ទុនបំរុង និងប្រាក់ចំណេញរក្សាទុក | ៦,៦០៨,៤៦៧ | ៦,០៥០,៨០០ | ៥,២៥៣,៣៥០ | ៥,៧៩៤,៧២០ |

## លទ្ធផលអាជីវកម្មក្នុងឆ្នាំ ( ដុល្លារអាមេរិក)

| | 2005 | 2004 | 2003 | 2002 |
|---|---|---|---|---|
| ចំណូលពីការប្រាក់( សុទ្ធ) | ៣,៨៨១,៧៣០ | ៣,០៦១,៤៨០ | ៩៩៤,៧៣៣ | ៩៥៥,៥០៦ |
| ចំណេញប្រតិបត្តិការមុនធ្វើសំវិធានធន | ៣,៧១៧,៩៨៦ | ៣,៦៧៥,៤៣០ | ២,០០០,៣៤៦ | ១,៩៩២,០៣៤ |
| ចំណេញមុនបង់ពន្ធ | ៨៩១,៤៥៦ | ១,៥៦៨,៩៣៩ | ៨៧៥,៨៤០ | ២,០៥៩,០៣៣ |
| ប្រាក់ចំណេញក្រោយពីបង់ពន្ធ | ៧៣៤,៣៧២ | ១,២៥៥,១៥១ | ៧០០,៦៧២ | ១,៦៣៨,៧១១ |



# លទ្ធផលអនុវត្តអាជីវកម្មក្នុងឆ្នាំ









# សាររបស់លោកប្រធានក្រុមប្រឹក្សាភិបាល



## សម្តេច ទ្រង់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាទីរាប់អាន

តាងនាមអោយក្រុមប្រឹក្សាភិបាលរបស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ខ្ញុំមានកិត្តិយសបង្ហាញជូនអតិថិជននូវរបាយការណ៍ប្រចាំឆ្នាំ សំរាប់ឆ្នាំសារពើពន្ធ ដែលបានបញ្ចប់ទៅ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ កន្លងទៅនេះ ។

ក្នុងឆ្នាំ២០០៥ ធនាគារមានព្រឹត្តិការណ៏សំខាន់ជាច្រើនដែលបង្ហាញនូវភស្តុតាងជាក់ស្តែងដូចជា ការបញ្ចប់ដោយជោគជ័យ នូវដំណើរការធ្វើឯកជនភាវូបនីយកម្មរបស់ធនាគារជាដើម ។ ធនាគារពាណិជ្ជរបស់រដ្ឋដែលមានតែមួយនៅកម្ពុជាបានក្លាយទៅជាធនាគារពាណិជ្ជរដ្ឋចំរុះឯកជន នៅឆ្នាំទី ២៦ នៃអត្ថិភាពរបស់ខ្លួន ។

ជាលទ្ធផលនៃព្រឹត្តិការណ៏សំខាន់នេះ បានផ្តល់ឱកាសអោយមានការប្រែប្រួលមុខមាត់ និងកាលានុវត្តភាពដល់ធនាគារ អតិថិជន និងបុគ្គលិករបស់ខ្លួន ។ ធនាគារមានគោលដៅចំបងពីរដែលបន្តពីដំណាក់កាលនេះ គឺជំរុញការផ្តល់ឥណទានសំរាប់ពាណិជ្ជករក្នុងស្រុក ។ ក្នុងនាមជាជនជាតិខ្មែរ យើងខ្ញុំបន្តធ្វើវិនិយោគនៅកម្ពុជា ។ យើងនឹងបញ្ចូលនយោបាយថ្មីក្នុងធនាគារ ដើម្បីកែប្រែមុខមាត់ នឹងកែលំអសេវាធនាគារ ព្រោះធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ត្រូវការដើរតួនាទីពេញលេញរបស់ខ្លួនក្នុងជីវភាពសង្គម និងសេដ្ឋកិច្ច ។

គោលដៅសំខាន់មួយគឺបង្កើត ប្រាក់ចំណេញអោយបានកាន់តែច្រើនថែមទៀត ដោយជំរុញការដាក់ចុះនូវផលិតផលថ្មី ការកាត់បន្ថយសោហ៊ុយ និងការកែលំអរបៀបរបបការងារ ។
យើងខ្ញុំរំពឹងថា នឹងដាក់ជូនអតិថិជនប្រើប្រាស់នូវម៉ាស៊ីនស្វ័យប្រវត្តិដកប្រាក់នៅអំឡុងឆមាសទី២នេះ ហើយជឿជាក់ថា សេវានេះនឹងជួយសំរួលទំនាក់ទំនងធុរកិច្ចប្រចាំថ្ងៃរបស់អតិថិជនជាមួយធនាគារ ។
វប្បធម៌របស់យើងគឺ ចងចាំជានិច្ចនូវផលប្រយោជន៏របស់អតិថិជន ។ យើងខ្ញុំនៅទីនេះដើម្បីបំរើអតិថិជន ហើយអតិថិជនមាន សិទ្ធិទាមទារពីយើងខ្ញុំនូវការប្រឹងប្រែងបំរើ និងសេវាដ៏ល្អបំផុត ។

នៅពេលដែលយើងផ្តល់ជូនអតិថិជននូវសេវាកាន់តែច្រើននៅក្នុង និងក្រៅស្រុក ពេលនោះធនាគារយើងកាន់តែទទួលបាននូវចំណូល ហើយពេលនោះដែរ នឹងមានការលើកទឹកចិត្តកាន់តែច្រើន សំរាប់បុគ្គលិកធនាគារ ។ ដូច្នេះ បុគ្គលិកធនាគារមានផលប្រយោជន៏ដោយផ្ទាល់ ទៅនឹងវិបុលភាពរបស់ធនាគារ ដោយទទួលបាននូវអត្ថប្រយោជន៏ច្រើនបំផុតអំពីចំណូលរបស់ធនាគារ ។

សរុបសេចក្តីមក ធ្វើការបំរើអតិថិជនមានន័យថាបំរើខ្លួនយើងដែរ ។ ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា មានកិត្តិយស និងមោទនភាពណាស់ ដែលជាចំណែកមួយនៃធុរកិច្ចប្រចាំថ្ងៃរបស់អតិថិជន និងជាចំណែកមួយនៃជីវភាពសេដ្ឋកិច្ចរបស់កម្ពុជា ។ យើងនៅតែបន្តចូលរួមចំណែកយ៉ាងសកម្មទៅទៀត នៅក្នុងការបង្កើនផលិតផលសរុបក្នុងស្រុក និងបង្កើនកំរឹតជីវភាពរស់នៅរបស់បុគ្គលិក ។ យើងខ្ញុំសង្ឃឹមថានឹងបានចូលរួមកាន់តែច្រើនឡើងទៀត ទៅនឹងការអភិវឌ្ឍន៏សេដ្ឋកិច្ចប្រទេសជាតិ ទោះជាមានហានិភ័យក្តី ។

ឆ្លៀតឱកាសនេះ យើងខ្ញុំសូមគោរពជូនពរ កោតសរសើរ និងកតញ្ញូតាដ៏កក់ក្តៅចំពោះការគាំទ្រជាបន្តបន្ទាប់ និងចំពោះទំនុកចិត្តរបស់សម្តេច ទ្រង់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ។

លោក ពុង ឃាវសែ
ប្រធានក្រុមប្រឹក្សាភិបាល



# សាររបស់អគ្គនាយក



ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា បានដើរតួនាទីឈានមុខមុនគេបង្អស់នៅក្នុងប្រទេសកម្ពុជា និងបានបំពេញតាមតំរូវការរបស់អតិថិជនជាតិ និងអន្តរជាតិនូវប្រតិបត្តិការសេវាកម្មធនាគារ ។

នៅត្រីមាសទី ៤ ឆ្នាំ ២០០៥ ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា បានក្លាយជាធនាគារពាណិជ្ជរដ្ឋចំរុះឯកជន ដែលបញ្ជាក់អោយឃើញថា ធនាគារបានចូលរួមចំណែកក្នុងការអនុវត្តន៏ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុសំរាប់ឆ្នាំ ២០០១-២០១០ របស់រាជរដ្ឋាភិបាលកម្ពុជា លើវិស័យធនាគារ ព្រមទាំងបានសំរេចទៅតាមទិសដៅរបស់ភាគទុនិករដ្ឋ ។

## ភាពរឹងមាំ និងស្ថេរភាព

ម្ភៃប្រាំមួយឆ្នាំកន្លងមកនេះ យើងនៅតែរក្សាបានភាពជឿទុកចិត្ត និងការគាំទ្រពីអតិថិជនរបស់យើង ជាក់ស្តែងទ្រព្យសកម្មរបស់ធនាគារកើនឡើងលើសពីឆ្នាំ ២០០៤ អាស្រ័យដោយមានការជឿទុកចិត្ត និងការគាំទ្រយ៉ាងសកម្មនេះ ជាលទ្ធផលបានបង្ហាញពីស្ថានភាព :

- កំណើនប្រាក់បញ្ញើមានដល់ ជាង ១៤៣ លាន ដុល្លារអាមេរិក
- ប្រាក់ចំណេញមុនធ្វើសំវិធានធនមានចំនួន ៣,៧១៧,០០០ ដុល្លារអាមេរិក

## ដំណើរឆ្ពោះទៅមុខរបស់យើង

យុទ្ធសាស្ត្រ និងគោលដៅជាចំបងសំរាប់ឆ្នាំ ២០០៦ រួមមាន :

- បន្តអភិវឌ្ឍបុគ្គលិករបស់យើង អោយមានទេពកោសល្យកាន់តែប្រសើរឡើង ដោយសង្កត់លើអាជីពផ្នែកធនាគារយូរអង្វែង
- បន្តកែសំរួលសេវាអតិថិជន និងពង្រីកបន្ថែមសេវាកម្មថ្មី ដែលជាជំរើសល្អបំផុតរបស់ប្រជាពលរដ្ឋកម្ពុជា
- បន្ត និងពង្រីកការប្រើប្រាស់មូលធន អោយមានប្រសិទ្ធិភាព ដើម្បីទទួលបាននូវប្រាក់ចំណេញកើនខ្ពស់ជាងឆ្នាំ ២០០៥
- បន្តអភិវឌ្ឍបន្ថែមនូវប្រព័ន្ធទូទៅ ដើម្បីផ្តល់ភាពងាយស្រួលជូនអតិថិជនមកធ្វើប្រតិបត្តិការជាមួយធនាគារយើង
- រក្សាអោយបាននូវសុវត្ថិភាពមូលធនមានស្រាប់ ជូនអតិថិជន និងបន្តស្រូបយកអតិថិជនថ្មី
- រក្សាអោយបានភាពជាធនាគារពាណិជ្ជមួយកាន់តែរឹងមាំ ក្នុងប្រតិបត្តិការធនាគារ នៅក្នុងបរិបទប្រកួតប្រជែងពាណិជ្ជកម្មខ្ពស់នៅក្នុងទីផ្សារកម្ពុជា ។

ជាចុងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះគណៈគ្រប់គ្រងដែលបានចូលរួមចំណែកនៅក្នុងការដាក់ចុះនូវដំណាក់កាលអន្តរកាលសន្សឹមៗ នេះ ជាពិសេស លោកប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល បានប្រមើលមើលអនាគត និងឆន្ទៈរបស់អស់លោកក្នុងការដឹកនាំធុរកិច្ចឆ្ពោះទៅកាន់វប្បធម៌សហគ្រាសថ្មី គឺជាប្រភពកំលាំងជំរុញទឹកចិត្តសម្រាប់យើងគ្រប់ៗគ្នា ។

សូមសំដែងអំណរគុណ ចំពោះមន្ត្រីបុគ្គលិកទាំងអស់ ដែលបានខិតខំប្រឹងប្រែងធ្វើអោយទស្សនៈវិស័យរបស់យើងក្លាយជាការពិត ។

យើងខ្ញុំសូមសំដែងកត្តញ្ញូតាធម៌ចំពោះ សម្តេច ទ្រង់ ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ដែលជាអតិថិជនទាំងអស់ តែងតែផ្តល់ការគាំទ្រ និងទំនុកចិត្តរបស់អស់លោកមកលើយើងខ្ញុំ ។ យើងខ្ញុំសង្ឃឹមថា នឹងមានកិត្តិយស នឹងមានមោទនភាព បន្តបំរើអស់លោកជានិច្ច ។

លោកជំទាវ អ៊ុក ម៉ាលី
អគ្គនាយក

# ក្រុមប្រឹក្សាភិបាល

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលជាអង្គការចាត់តាំងកំពូល តំណាងមហាសន្និបាត ភាគទុនិកបង្កើតជា មហាសន្និបាតសាមញ្ញ និងវិសាមញ្ញ ។

### ក្រុមប្រឹក្សាភិបាលធនាគារមានសមាជិកចំនួន ៦រូប ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| លោក ពុង ឃាវសែ | ប្រធានក្រុមប្រឹក្សាភិបាល | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០៥ |
| ឧកញ៉ា លឹម ប៊ុនសួរ | អនុប្រធានក្រុមប្រឹក្សាភិបាល | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០៥ |
| លោក ម៊ី វ៉ាន់ | សមាជិកក្រុមប្រឹក្សាភិបាល | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០២ |
| លោកជំទាវ អ៊ុក ម៉ាលី | សមាជិកក្រុមប្រឹក្សាភិបាល | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០០ |
| ឯកឧត្តម ហ៊ី អានវ៉ានិថ | សមាជិកក្រុមប្រឹក្សាភិបាល | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០៥ |
| លោកជំទាវ អ៊ឹង ប៉ូលីណា | សមាជិកក្រុមប្រឹក្សាភិបាល | ចូលជាសមាជិកក្រុមប្រឹក្សាភិបាលឆ្នាំ២០០៥ |

# គណៈគ្រប់គ្រងប្រតិបត្តិ

គណៈគ្រប់គ្រងប្រតិបត្តិធនាគារមានតួនាទី-ទទួលខុសត្រូវគ្រប់គ្រង ប្រតិបត្តិការអាជីវកម្មធនាគារ ទាំងមូល ។

### គណៈគ្រប់គ្រងប្រតិបត្តិធនាគារមានចំនួន០៥ :

| | |
|---|---|
| លោកជំទាវ អ៊ុក ម៉ាលី | អគ្គនាយក |
| ឯកឧត្តម ហ៊ី អានវ៉ានិថ | អគ្គនាយករង |
| លោក ទឹម បូផល | អគ្គនាយករង |
| លោក ផង់ សំរេច | អគ្គនាយករង |
| លោកជំទាវ អ៊ឹង ប៉ូលីណា | ប្រធានសវនកម្មផ្ទៃក្នុង |

# គណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម (ALCO)

### គណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម មានសមាជិកចំនួន០៩រូប

| | | |
|---|---|---|
| លោកជំទាវ អ៊ុក ម៉ាលី | អគ្គនាយក | ប្រធាន |
| ឯកឧត្តម ហ៊ី អានវ៉ានិថ | សមាជិកក្រុមប្រឹក្សាភិបាល | អនុប្រធាន |
| លោក ទឹម បូផល | អគ្គនាយករង | សមាជិក |
| លោក ផង់ សំរេច | អគ្គនាយករង | សមាជិក |
| លោកជំទាវ អ៊ឹង ប៉ូលីណា | សមាជិកក្រុមប្រឹក្សាភិបាល | សមាជិក |
| ប្រធាននាយកដ្ឋានអន្តរជាតិ | | សមាជិក |
| ប្រធាននាយកដ្ឋានសេវាអតិថិជន | | សមាជិក |
| ប្រធាននាយកដ្ឋានគណនេយ្យ | | សមាជិក |
| ប្រធាននាយកដ្ឋានឥណទាន | | សមាជិក |

# គណៈកម្មការឥណទានធនាគារ

### ដោយមានការកែទម្រង់ធំៗនៅធនាគារក្នុងឆ្នាំ ២០០៥ សមាសភាពគណៈកម្មការថ្មីផ្នែកឥណទានមានដូចតទៅ :

| | | |
|---|---|---|
| ឧកញ៉ា លឹម ប៊ុនសួរ | អនុប្រធានក្រុមប្រឹក្សាភិបាល | ប្រធាន |
| លោកជំទាវ អ៊ុក ម៉ាលី | អគ្គនាយក | សមាជិក |
| ឯកឧត្តម ហ៊ី អានវ៉ានិថ | អគ្គនាយករង | សមាជិក |
| លោក ទឹម បូផល | អគ្គនាយករង | សមាជិក |
| លោក ជំទាវ អ៊ឹង ប៉ូលីណា | សមាជិកក្រុមប្រឹក្សាភិបាល | សមាជិក |





# ប្រវត្តិរូបរបស់គណៈគ្រប់គ្រង

**១ លោក ពុង ឃាវសែ ប្រធានក្រុមប្រឹក្សាភិបាល**

លោកកើតនៅឆ្នាំ១៩៤៦ នៅភ្នំពេញ ប្រទេសកម្ពុជា ។ ដោយសារទេពកោសល្យ និងមានបទពិសោធន៍ដ៏ច្រើន លោកបានទទួលកិត្តិយស និងការគោរពជាច្រើន ។ លោកបានចូលរួមយ៉ាងសកម្ម ក្នុងសកម្មភាពសេដ្ឋកិច្ចទូលំទូលាយទាំងខាងក្រៅ និងក្នុងប្រទេស ។ លោកមានស្នាដៃជាច្រើន ក្នុងនោះមានការចូលរួមអភិវឌ្ឍប្រទេសកម្ពុជាយ៉ាងសំខាន់ៗ ដោយបានព្រះមហាក្សត្រកម្ពុជា នរោត្តមសីហនុ ទទួលស្គាល់ដោយប្រទានមេដាយមហាសិរីវឌ្ឍនៈ នៅឆ្នាំ ២00២ ។

**២ ឧកញ៉ា លឹម ប៊ុនសួរ អនុប្រធានក្រុមប្រឹក្សាភិបាល**

លោកឧកញ៉ាកើតនៅឆ្នាំ ១៩៦៥ នៅខេត្តកំពង់ឆ្នាំង ប្រទេសកម្ពុជា ។ លោកឧកញ៉ាជាធុរជនល្បីល្បាញ និងទទួលការគោរពច្រើន មានបទពិសោធន៍ខ្ពស់នៅក្នុងអាជីពរបស់លោក ។ បច្ចុប្បន្ន លោកឧកញ៉ាជាអនុប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន AZ Group សមាជិកសភាពាណិជ្ជកម្ម នៃកម្ពុជា សមាជិកក្រុមប្រឹក្សាភិបាលសហគ្រាសសាធារណៈទូរគមនាគមន៍កម្ពុជា TC និងប្រធានក្រុមប្រឹក្សាភិបាលកាំមីងតែល ។

**៣ លោក ម៉ី វ៉ាន់ សមាជិកក្រុមប្រឹក្សាភិបាល**

លោកកើតនៅឆ្នាំ ១៩៦៩ នៅខេត្តកំពង់ធំ ប្រទេសកម្ពុជា ។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច និងបានចូលរួមសិក្ខាសាលាច្រើនទាំងក្នុង និងក្រៅប្រទេស ក្រោមប្រធានបទទាក់ទងទៅនឹងទីផ្សារហិរញ្ញវត្ថុ និងផ្នែកអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅកម្ពុជា ។ បច្ចុប្បន្នជា ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**៤ លោកជំទាវ អ៊ុក ម៉ាលី សមាជិកក្រុមប្រឹក្សាភិបាល**

លោកជំទាវកើតនៅឆ្នាំ ១៩៥១ នៅខេត្តតាកែវ ប្រទេសកម្ពុជា បានបញ្ចប់ការសិក្សាដោយជោគជ័យ ថ្នាក់មធ្យមបច្ចេកទេសធនាគារនៅឆ្នាំ ១៩៨៤ និងបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម នៅឆ្នាំ ១៩៩៧ ។ លោកជំទាវ បានឆ្លងកាត់ការរៀនសូត្រដកពិសោធន៍វិស័យធនាគារ វគ្គវែង-ខ្លីនៅក្រៅប្រទេសជាច្រើន ។ លោកជំទាវមានចំណេះដឹងជំនាញផ្នែកធនាគារ ហើយនៅក្នុងអាជីពយូរលង់របស់លោកជំទាវ បានបង្រៀន និងចែករំលែកបទពិសោធន៍ ជាមួយធនាគារបរទេស ។ លោកជំទាវជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃប្រទេសកម្ពុជា មានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ និង ជាអគ្គហិរញ្ញិកកាកបាទក្រហមកម្ពុជា ។ លោកជំទាវបានបំរើការនៅ ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជាចាប់តាំងពីឆ្នាំ ១៩៧៩ ហើយពីឆ្នាំ ២000 ដល់បច្ចុប្បន្ន លោកជំទាវជាអគ្គនាយកធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ។

**៥ ឯកឧត្តម ហ្គី អានវ៉ានិថ សមាជិកក្រុមប្រឹក្សាភិបាល**

ឯកឧត្តមកើតនៅឆ្នាំ ១៩៥៣ នៅប្រទេសកម្ពុជា ។ ឯកឧត្តមមានបរិញ្ញាប័ត្រវិស្វកម្ម និងវិទ្យាសាស្ត្រអនុវត្ត (វិស្វកម្មឧស្សាហកម្ម) ឆ្នាំ១៩៧៦ ពី Ecole Polytechnique, University of Montreal ប្រកបដោយនិទ្ទេសកិត្តិយស ។ នៅឆ្នាំ ១៩៨0 ឯកឧត្តម បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម ពីសកលវិទ្យាល័យ University of Western Ontario in Canada ។ ឯកឧត្តមមានបទពិសោធន៍ជាច្រើនឆ្នាំ នៅក្នុងផ្នែកច្រើនៈ ផ្នែកធនាគារ (ធនាគារតូរ៉ុងតូ Dominion, ធនាគារម៉ុងរ៉េអាល, Credit Agricole Indosuez, ANZ Royal, MPDF) ផ្នែកហិរញ្ញវត្ថុ (Laurentian Group-Banking and Insurance-Canada) ផ្នែកវិស្វកម្ម (Bechtel Corporation, USA) ផ្នែកក្រុមហ៊ុន (ក្រុមហ៊ុនសម្បទានិក អាកាសយានដ្ឋាន/Vinci និងផ្នែករដ្ឋាភិបាល (ក្រសួងសាធារណៈការ និងដឹកជញ្ជូន កំពង់ផែស្វយ័តក្រុងព្រះសីហនុ) ។

**៦ លោកជំទាវ អ៊ឹង ប៉ូលីណា សមាជិកក្រុមប្រឹក្សាភិបាល**

លោកជំទាវកើតឆ្នាំ ១៩៦0 នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ លោកជំទាវបានបញ្ចប់ការសិក្សាពី Normandy Business School (ESCAE-Le Havre-Caen)-France និងពីមជ្ឈមណ្ឌល Normandy សំរាប់ការស្រាវជ្រាវស្តីពីវិទ្យាសាស្ត្រកុំព្យូទ័រ (CENORI) ។ លោកជំទាវមានបទពិសោធន៍ជាពិសេស នៅក្នុងការគ្រប់គ្រងធនធានមនុស្ស ព័ត៌មានវិទ្យា គណនេយ្យ ច្បាប់ និងធនាគារ ។

**៧ លោក ទឹម បូផល អគ្គនាយករង**

លោកកើតនៅឆ្នាំ១៩៥0នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា បានបញ្ចប់ការសិក្សាបរិញ្ញាប័ត្រ ផ្នែកសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា និងបានឆ្លងកាត់ដោយជោគជ័យនូវវគ្គសិក្សាជាច្រើនស្តីពីហិរញ្ញវត្ថុ និងធនាគារនៅក្នុង និងក្រៅប្រទេស ។

**៨ លោក ផង់ សំរេច អគ្គនាយករង**

លោកកើតនៅឆ្នាំ១៩៤៨ នៅទីក្រុងភ្នំពេញប្រទេសកម្ពុជា បានបញ្ចប់ការសិក្សាបរិញ្ញាប័ត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីប្រទេសវៀតណាម និងបានឆ្លងកាត់ដោយជោគជ័យនូវវគ្គសិក្សាជាច្រើន ក្រោមប្រធានបទដែលទាក់ទងនឹងហិរញ្ញវត្ថុ និងធនាគារនៅក្នុងនិងក្រៅប្រទេស ។



*ជួរមុខ (ពីឆ្វេងទៅស្តាំ)៖* ឧកញ៉ា លឹម ប៊ុនសួរ លោក ពុង ឃាវសែ
*ជួរក្រោយ (ពីឆ្វេងទៅស្តាំ)៖* លោកជំទាវ អ៊ឹង ប៉ូលីណា ឯកឧត្តម ហ្គី អានវ៉ានិថ លោក ម៉ី វ៉ាន់ លោកជំទាវ អ៊ុក ម៉ាលី

# របាយការណ៍ក្រុមប្រឹក្សាភិបាល

## សវនកម្មផ្ទៃក្នុង

ធនាគារពាណិកម្មក្រៅប្រទេស នៃកម្ពុជា មានផ្នែកសវនកម្មផ្ទៃក្នុងដែលរៀបចំបានល្អមួយ ។ សវនកម្មផ្ទៃក្នុងជាជំនួយការរបស់ក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យបណ្តានាយកដ្ឋាននានារបស់ធនាគារ និងកែលំអលទ្ធផលអនុវត្តការងារអោយកាន់តែប្រសើរឡើង ដោយធ្វើការវាយតម្លៃជាទៀងទាត់ ទៅតាមកម្មវិធីសវនកម្មលើវិស័យប្រតិបត្តិការនានាព្រមទាំងផ្តល់អនុសាសន៍ក្នុងការកែលំអ ។

## ការគ្រប់គ្រងហានិភ័យ

គណៈកម្មការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម (អាល់កូ) របស់ធនាគារទទួលខុសត្រូវគ្រប់គ្រងហានិភ័យធនាគារ រាយការណ៍អំពីហានិភ័យធំៗ និងធានាថា ធនាគារគោរពតាមបទបញ្ញត្តិផ្ទៃក្នុងធនាគារ ព្រមទាំងការទាមទាររបស់ធនាគារជាតិ នៃកម្ពុជា ជាពិសេសអ្វីដែលទាក់ទងទៅនឹងសាធនភាព និងសាច់ប្រាក់ងាយស្រួល ។ គណៈកម្មការនេះទទួលខុសត្រូវធានាថា ត្រួតពិនិត្យ និងវិភាគជាប្រចាំលើបរិស្ថានធុរកិច្ច ដើម្បីធ្វើការកែប្រែចាំបាច់ ទាន់ពេលនូវគោលនយោបាយ ឬនីតិវិធីគ្រប់គ្រងហានិភ័យរបស់ធនាគារ ប្រកបដោយសុក្រិតភាព ។

នៅអំឡុងឆ្នាំ ២០០៥ការកែលំអពិសេសៗត្រូវបានកំណត់នៅក្នុងវិស័យគ្រប់គ្រងហានិភ័យ ។ ជាលទ្ធផល គណៈគ្រប់គ្រងធនាគារនឹងកំណត់អាទិភាព និងត្រួតពិនិត្យការជំរុញវិសោធនកម្មគោលនយោបាយនិងនីតិវិធីគ្រប់គ្រង ហានិភ័យនៅក្នុងអំឡុងពេលខាងមុខនេះដោយផ្តោតទៅលើ :

- ការពិនិត្យឡើងវិញរបាយការណ៍សាច់ប្រាក់ងាយស្រួលជាប្រចាំថ្ងៃដើម្បីធានាការត្រួតពិនិត្យឱ្យបានរឹងរិតតែម៉ឹងម៉ាត់ឡើង ។
- ការរៀបចំផែនការរឹងមាំសំរាប់ទប់ទល់ព្រឹត្តិការណ៍ជាយថាហេតុនៃការខ្វះសាច់ប្រាក់ងាយស្រួល ។
- ការរក្សាទុកជាប្រចាំនូវលំហូរសាច់ប្រាក់ងាយស្រួលឱ្យបានច្រើន និងការអនុវត្តន៍តាមប្រកាសលេខ ធ.០៧.០០.៣៨ របស់ធនាគារជាតិនៃកម្ពុជា ។
- ការកែលំអជាប្រចាំនូវគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យអត្រាការប្រាក់តាមរយៈ ការវិភាគ Gap Analysis ។
- ការកំណត់ព្រំដែនសកម្មភាពប្តូរប្រាក់ និងការដាក់អនុវត្តនូវនីតិវិធីបង្ការភាពមិនស៊ីគ្នារវាងរូបិយប័ណ្ណនីមួយៗ ដែលទ្រព្យសកម្ម និងអកម្មត្រូវបានចុះបញ្ជី ។
- ការរៀបចំរបៀបរាយការណ៍ប្រកបដោយតម្លាភាពទៅកាន់ និងចេញពីនាយកដ្ឋាននីមួយៗរួមមានចេញពីផ្នែកសវនកម្មផ្ទៃក្នុងជូនទៅក្រុមប្រឹក្សាភិបាល ។
- ការរៀបចំគោលនយោបាយ និងនីតិវិធីសវនកម្មផ្ទៃក្នុង អោយស្របទៅនឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង របស់ធនាគារ ។
- ការរៀបចំ និងចែកចាយសៀវភៅណែនាំផ្ទៃក្នុងមួយ សំរាប់បុគ្គលិកធនាគារប្រើប្រាស់ជាមគ្គុទេសន៍នៅក្នុងការអនុវត្តន៍កិច្ចការប្រចាំថ្ងៃ ។
- ការរចនា និងការដាក់អនុវត្តនូវកម្មវិធីបណ្តុះបណ្តាលទូលំទូលាយដើម្បីបុគ្គលិកអភិវឌ្ឍសមត្ថភាពគ្រប់គ្រងហានិភ័យរបស់ខ្លួន ។

## ការប្រែប្រួលសំខាន់ៗនៅក្នុងឆ្នាំ

នៅក្នុងឆ្នាំ ២០០៥ យើងមានការផ្លាស់ប្តូរសំខាន់ៗជាច្រើន ហើយប្រការនេះ នាំអោយមានការកែប្រែមុខមាត់ និងរបៀបរបបធ្វើធុរកិច្ចរបស់ធនាគារ ។ ដោយចាប់ផ្តើមពីការធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជមួយធនាគារបានបង្ហាញយើង នូវការជំនះលើឧបសគ្គជាច្រើន តែនៅពេលនេះធនាគារអាចជួបនិងកាលានុវត្តភាពច្រើនជាងមុន ធំៗជាងមុន និងគួរអោយរំភើបទៀតផង ។ ការប្រែប្រួលដ៏សំខាន់ជាងគេមួយ គឺការប្រកាសនាចុងឆ្នាំ២០០៥ របស់ក្រុមប្រឹក្សាភិបាល ទៅដល់បុគ្គលិកពីការចាប់ផ្តើមស្តារកេរ្តិ៍ឈ្មោះ យីហោធនាគារឱ្យកាន់តែភ្លឺថ្លាឡើង ។ វិសាលភាពនៃគំរោងនេះនឹងត្រូវរៀបចំបញ្ចប់ ប៉ុន្តែជំហានទីមួយនៃកិច្ចការនេះគឺជាការរចនាផ្លាកសញ្ញាថ្មីមួយ ។ នៅពេលគំនិតផ្តួចផ្តើមនេះលេចចេញជារូបរាងពេញលេញមក វានឹងជួយអោយយើងត្រៀមលក្ខណៈផ្លូវចិត្តសម្រាប់ការយកជ័យជំនះលើការប្រកួតប្រជែងឆ្ពោះទៅខាងមុខ និងធ្វើអោយយើងផ្តោតការយកចិត្តទុកដាក់ទៅលើបេសកកម្មរបស់យើង និងជួយអោយយើងផ្សព្វផ្សាយទៅកាន់អតិថិជនរបស់យើងថា អ្វីទៅជាធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ថ្មី និងកែលំអរួចហើយនេះ ។ ទាំងនេះជាសេចក្តីសង្ខេបនៃការប្រែប្រួលដែលយើងបានធ្វើ :

- ធ្វើអោយសេវាកម្មរបស់យើងមានលក្ខណៈកាន់តែរហ័សទាន់ចិត្តឡើងសំរាប់បំរើអតិថិជនដោយប្រព័ន្ធ Core Banking System (CBS) ថ្មី ។
- បុគ្គលិកធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា បានធ្វើការកែទំរង់រួចជាស្រេចដើម្បីកែលំអប្រសិទ្ធិភាព និងទិន្នផលការងារនៅក្នុងការផ្តល់សេវាកម្មធនាគារ ។
- បានរៀបចំគោលនយោបាយឥណទានសំរាប់នាយកដ្ឋានឥណទានដើម្បីពង្រីកសកម្មភាពឱ្យខ្ចីរបស់ខ្លួន និងបង្កើនគុណភាពទ្រព្យសកម្ម ។
- បានរៀបចំសេចក្តីណែនាំផ្នែកគណនេយ្យ នីតិវិធីការទូទាត់អន្តរជាតិ និងសេវាអតិថិជន និងជំរុញអោយចេញសៀវភៅសំរាប់បុគ្គលិក និងនីតិវិធីទប់ស្កាត់ និងការពារការសំអាតប្រាក់ ។

## ការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ធនាគារបានប្តេជ្ញាកែលំអ និងអភិវឌ្ឍផលិតផលសេវា និងបុគ្គលិករបស់ធនាគារ ព្រមទាំងបន្តការកែលំអទៅទៀតដើម្បីរក្សាទីតាំងដ៏សំខាន់របស់ខ្លួននៅក្នុងវិស័យហិរញ្ញវត្ថុ និងធនាគារនៅកម្ពុជា ។ ដើម្បីសម្រេចគោលដៅទាំងនេះ ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកធនាគារបាន និងកំពុងមានទិសដៅអនុវត្តដូច ខាងក្រោម :

- ផ្តើមដាក់ចុះអោយអនុវត្តនូវប្រព័ន្ធថ្មីនៃ Core Banking System ដែលនឹងនាំទៅដល់ការដាក់បញ្ចូលអោយប្រើនូវម៉ាស៊ីនស្វ័យប្រវត្តិដកប្រាក់ ATM និងសមត្ថភាពអនុវត្តសេវាធនាគារតាមប្រព័ន្ធអ៊ីនធឺណិត ។
- ការវាយតម្លៃសក្តានុពលភាពនៃផលិតផល និងសេវាថ្មីៗផ្សេងទៀតនៅពេលខាងមុខឆាប់ៗ ដោយអាស្រ័យសមត្ថភាពផ្នែកបច្ចេកវិទ្យារបស់ធនាគារ តម្រូវការនៃទីផ្សារហិរញ្ញវត្ថុ លទ្ធភាពនៃថវិកាអាចយកមកប្រើបាន និងសមត្ថភាពរបស់បុគ្គលិកធនាគារ ។
- ធានាថា បុគ្គលិកបានទទួលការបណ្តុះបណ្តាលដើម្បីឈានទៅដល់កំរិតស្តង់ដារអន្តរជាតិ ។





- ជំរុញ ទទួលស្គាល់ និងផ្តល់រង្វាន់ដល់លទ្ធផលអនុវត្តការងារប្រចាំថ្ងៃរបស់បុគ្គលិកខ្លួន ក្នុងការប្រតិបត្តិប្រកបដោយក្រមសីលធម៌ ភាពសុចរិត គុណធម៌ស្អាតស្អំ និងការយល់ព្រមការទទួលខុសត្រូវបន្ថែមទៀត ។
- កសាងទំនុកចិត្តបុគ្គលិកទៅលើអនាគតធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា និងលើកាលានុវត្តភាពក្នុងការអភិវឌ្ឍន៍អាជីពរបស់ពួកគេ ។ ធ្វើការអភិវឌ្ឍន៍វប្បធម៌ជាសមាជិកភាពរបស់បុគ្គលិកចំពោះធនាគារ និងបង្កើតបរិស្ថានការងារ ដែលធ្វើអោយបុគ្គលិកមានមោទនភាព និងធ្វើការនិងជំរុញការបង្កើនកំរិតទទួលខុសត្រូវ និងគំនិតផ្តួចផ្តើម ព្រមទាំងការរំភើបរីករាយក្នុងការងារ ។
- ដាក់ចុះអនុវត្តប្រព័ន្ធផ្តល់រង្វាន់ ដើម្បីធានាថា បុគ្គលិកទទួលបានការប៉ះប៉ូវប្រកបដោយយុត្តិធម៌សម្រាប់ការប្រឹងប្រែងរបស់ពួកគេ មានន័យថា មានការតម្លើងប្រាក់បៀវត្សនៅពេលវេលាសមស្របដោយរក្សាទុកនូវអត្ថប្រយោជន៍ដែលមានស្រាប់ ។

## ក្រមសីលធម៌

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ជាស្ថាប័នមួយដែលមានការទទួលស្គាល់ច្រើននៅក្នុងសហគមន៍ ។ ដើម្បីធានាថា យើងរក្សាកេរ្តិ៍ឈ្មោះដ៏ល្អនេះបាន ធនាគារនឹងបង្ហាញនូវកំរិតខ្ពស់បំផុតនៃសីលធម៌សង្គមធម៌ ចរិយាធម៌ នៅគ្រប់ពេលទាំងអស់ ។ ដើម្បីជួយអោយបុគ្គលិកផ្សារភ្ជាប់ទៅនឹងគោលការណ៍ទាំងនេះនៅក្នុងការងារប្រចាំថ្ងៃរបស់ខ្លួន ធនាគារបានរៀបចំគោលនយោបាយ និងនីតិវិធី អនុវត្តការងារដ៏ល្អបំផុតជាលាយលក្ខអក្សរ សំរាប់អោយបុគ្គលិកអនុវត្តតាម ។ នីតិវិធីទាំងនេះគូសបញ្ជាក់ពីការអនុវត្តន៍ការងារត្រឹមត្រូវ បទបញ្ជារបស់ធនាគារ និងក្រមសីលធម៌ ។ សៀវភៅទាំងនេះ ជាឯកសារបន្ថែមសំរាប់បណ្តុះបណ្តាលរបស់បុគ្គលិក ។

## ឯករាជ្យភាព និងតម្លាភាព

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ជាស្ថាប័នមានឯករាជ្យភាពពេញលេញ ។ ធនាគារបំពេញការងារ ជាធនាគារពាណិជ្ជមួយហើយក្នុងនាមជាធនាគារពាណិជ្ជ សកម្មភាពអាជីវកម្មរបស់ខ្លួនត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យប្រចាំគ្រាដល់ទីកន្លែង និងលើឯកសារពីធនាគារជាតិនៃកម្ពុជា ។

ដើម្បីធានាតម្លាភាពប្រតិបត្តិការ ធនាគារត្រូវបានត្រួតពិនិត្យពីសំណាក់សវនកម្មផ្ទៃក្នុងរបស់ខ្លួនផ្ទាល់ ។ ជាបន្ថែមទៀត ធនាគារទទួលការត្រួតពិនិត្យពីធនាគារជាតិនៃកម្ពុជា ដែលជាអាជ្ញាធររូបិយវត្ថុជាតិសំរាប់ធនាគារពាណិជ្ជទាំងអស់ ។ ទោះបីមានការត្រួតពិនិត្យជាប្រចាំយ៉ាងនេះទៅហើយក្តី ក៏ធនាគារជាកម្មវត្ថុនៃការស្រាវជ្រាវពិនិត្យប្រចាំឆ្នាំ ពីសំណាក់សវនកម្មឯករាជ្យ ។ សវនកម្មឯករាជ្យនេះ ត្រួតពិនិត្យរាល់ទិដ្ឋភាពហិរញ្ញវត្ថុនៃប្រតិបត្តិការទាំងអស់ ផ្តល់របាយការណ៍បញ្ជាក់អំពីការរកឃើញរបស់ពួកគេ និងធ្វើការបញ្ជាក់លើគណនីរបស់យើងថា បានគោរពទៅតាមតម្រូវការនៃច្បាប់ទាំងអស់ ។

# របាយការណ៍ក្រុមប្រឹក្សាភិបាល ( ត)

### អតិថិជន

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ខិតខំផ្តល់ការប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីផ្តល់សេវាជាទីទុកចិត្ត និងប្រកបដោយប្រសិទ្ធិភាពជូនទៅអតិថិជនរបស់យើងនៅគ្រប់ពេលវេលា ។ ទោះបីជាយ៉ាងនេះក្តីក៏យើងតែងតែទទួលស្គាល់ថា នៅមានការខ្វះចន្លោះ ដូច្នេះហើយទើបយើងខ្ញុំតែងតែស្វាគមន៍ចំពោះការវាយតំលៃ និងមតិយោបល់កែលំអពីសំណាក់អតិថិជនរបស់យើងជានិច្ច ។ យើងប្តេជ្ញាធ្វើការវាយតម្លៃ និងធ្វើការលើមតិយោបល់ទាំងនេះអោយអស់ពីលទ្ធភាព ។

### បុគ្គលិក

ដើម្បីក្លាយជាធនាគារជួរមុខគេនៅកម្ពុជា ក្រុមប្រឹក្សាភិបាល និងភាគទុនិកយល់ថា ការជ្រើសរើស និងការរក្សាទុកបុគ្គលិកដែលមានគុណភាពថ្នាក់កំពូល យោលទៅលើចំណេះដឹង ជំនាញ ឯកទេស និងការលើកទឹកចិត្តជាអាទិភាពចំបង ។ បៀវត្ស រង្វាន់ និងការអភិវឌ្ឍន៍បុគ្គលិកដើរតួនាទីយ៉ាងសំខាន់នៅក្នុងសមត្ថភាពរបស់យើង ដើម្បីសម្រេចគោលដៅនេះ ។

បុគ្គលិកទាំងអស់តែងតែបានទទួលការបណ្តុះបណ្តាលនៅក្នុងធនាគារ ឬនៅក្រៅប្រទេស នៅអំឡុងពេលកែទំរង់ និងអំឡុងនៃការដាក់អោយអនុវត្តកម្មវិធីអភិវឌ្ឍធនធានមនុស្សដែលបានរៀបចំនៅឆ្នាំ ២០០៤ ហើយយើងសង្ឃឹមថានឹងបានធនធានមនុស្សមានជំនាញចំរុះ មានសមត្ថភាពឆ្លើយតបដោយប្រសិទ្ធិភាពទៅនិងការផ្លាស់ប្តូរ ។

### ការចូលរួមវិភាគទានដល់សង្គម និងសហគមន៍

ដូចពីមុនមកដែរ ធនាគារបន្តការចូលរួមចំណែកជួយសហគមន៍ និងបុព្វហេតុសង្គមនៅក្នុងឆ្នាំ២០០៥ ។ យើងយកចិត្តទុកដាក់ជាសំខាន់ទៅលើកាកបាទក្រហមកម្ពុជា តែយើងក៏បានចូលរួមសកម្មភាពអង្គការសប្បុរសធម៌ផ្សេងៗ តូចជាងនេះដែរ ព្រមទាំងបានផ្តល់មូលនិធិដល់ពិធីបុណ្យប្រពៃណីជាតិទៀតផង ។

### ការអនុវត្តន៍ស្របទៅនឹងបទបញ្ញត្តិ និងច្បាប់នានារបស់ធនាគារជាតិ នៃកម្ពុជា

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា តែងតែយកចិត្តទុកដាក់ និងអនុវត្តតាមច្បាប់ និងបទបញ្ញត្តិនានារបស់ធនាគារជាតិ នៃកម្ពុជា ដូចជា :

- ការអនុវត្តន៍ប្លង់គណនេយ្យថ្មី របស់ធនាគារជាតិ នៃកម្ពុជា
- អនុបាតសាច់ប្រាក់ងាយស្រួល ប្រកាសលេខ ធ ៧-០៤-២០៧
- កាតព្វកិច្ចដើមទុនអប្បបរមា ប្រកាសលេខ ធ ៧-០០-៣៩
- មូលនិធិផ្ទាល់សុទ្ធ ប្រកាសលេខ ធ ៧-០០-៤៧
- អនុបាតសាធនភាព ប្រកាសលេខ ធ ៧-០៤-២០៦
- ចំណាត់ថ្នាក់ និងសំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទាន ប្រកាសលេខ ធ ៧០០-៥១ និងការកែតំរូវតាម ប្រកាសលេខ ធ៧-០២-១៤៥ និង សារាចរ លេខ ធ៧-០៤-០១
- ឥណទានធំៗ ប្រកាសលេខ ធ ៧០០-៥២
- ឥណទានចំពោះសម្ព័ន្ធញាតិ ប្រកាសលេខ ធ ៧-០២-១៤៦
- អចលនទ្រព្យ ប្រកាសលេខ ធ ៧-០១-១៨៦



# របាយការណ៍ហិរញ្ញវត្ថុ របស់ស្នងការគណនីឯករាជ្យឆ្នាំ ២០០៥

## របាយការណ៍របស់គណៈគ្រប់គ្រងប្រតិបត្តិ

គណៈគ្រប់គ្រងប្រតិបត្តិឧទ្ទេសនាមរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានត្រួតពិនិត្យរួចរបស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ហៅកាត់ថា ធនាគារ សំរាប់ឆ្នាំដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ។

### ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ត្រូវបានបង្កើតឡើងតាមអនុក្រិត្យលេខ ១២១៣ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៧៩ ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ក្នុងឆ្នាំ ២០០០ ធនាគារបានផ្តាច់ចេញពីការគ្រប់គ្រងដោយផ្ទាល់ពីធនាគារជាតិ នៃកម្ពុជា ("ធនាគារកណ្តាល") ដើម្បីប្រែក្លាយខ្លួនទៅជាធនាគារពាណិជ្ជរបស់រដ្ឋមានលក្ខណៈជាសហគ្រាសសេដ្ឋកិច្ចសាធារណៈ ហើយមានគោលដៅធ្វើប្រតិបត្តិការអាជីវកម្មស្វយ័ត ។ នៅពេលដែលការគ្រប់គ្រង និងប្រតិបត្តិការបច្ចេកទេសត្រូវបានពង្រឹង និងកែលំអដោយគណៈកម្មការកែទំរង់ធនាគារ និងមានលក្ខណៈសម្បត្តិស្មើនឹងធនាគារពាណិជ្ជដទៃទៀត ។

ក្នុងខែ មករា ឆ្នាំ ២០០១ ធនាគារបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មពីធនាគារជាតិ ដើម្បីធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជ ក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានសុពលភាព ៣ ឆ្នាំ មានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០០១ ។ នេះគឺជាអាជ្ញាប័ណ្ណ លើកដំបូងដែលត្រូវបានផ្តល់អោយ ដើម្បីជំរុញអោយធនាគារធ្វើប្រតិបត្តិការជានីតិបុគ្គលដែលមានឯករាជ្យភាពពីការគ្រប់គ្រងដោយផ្ទាល់ពីធនាគារកណ្តាល ។ នៅថ្ងៃទី ៨ មករា ២០០៤ ធនាគារបានទទួលយកអាជ្ញាប័ណ្ណលើកទី ២ របស់ខ្លួនពីធនាគារជាតិនៃកម្ពុជា សំរាប់រយៈពេលបីឆ្នាំ ចាប់ពីថ្ងៃនេះតទៅ ។

នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ("ក្រ.សហវ") បានប្រកាសនូវរបាយការណ៍ ស្តីពីគោលបំណងធ្វើឯកជនភាវូបនីយកម្មរបស់ធនាគារ ដែលជាផ្នែកមួយនៃកម្មវិធីកំណែទំរង់វិស័យហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាលកម្ពុជា ។ នៅ ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០៥ ភាគទុនិករបស់ធនាគារ ដែលតំណាងដោយគណៈកម្មាធិការ ឯកជនភាវូបនីយកម្ម បានចុះកិច្ចព្រមព្រៀងលក់ធនាគារ ជាមួយនឹងធនាគារកាណាឌីយ៉ា និងក្រុមហ៊ុន អាយអិនជីហូលឌីង ។ ធនាគារកណ្តាលបានលក់ភាគហ៊ុន ២០% របស់ខ្លួន និង ក្រ.សហវ បានបន្ថយភាគហ៊ុនរបស់ខ្លួនពីចំនួន ៨០% មក ១០% វិញ ។ ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០០៦ លក្ខន្តិកៈរបស់ធនាគារត្រូវបានធ្វើវិសោធនកម្ម ដើម្បីឆ្លុះបង្ហាញពីការប្រែប្រួលភាគទុនិក ។

### សកម្មភាពសំខាន់ៗ

សកម្មភាពសំខាន់ៗរបស់ធនាគាររួមមាន ការធ្វើប្រតិបត្តិការធនាគារច្រើនប្រភេទ និង សេវាកម្មហិរញ្ញវត្ថុ ដែលពាក់ព័ន្ធ ។

### លទ្ធផល នៃប្រតិបត្តិការនិងប្រាក់ចំណេញ

លទ្ធផលនៃប្រតិបត្តិការសំរាប់ឆ្នាំដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ត្រូវបានរៀបចំក្នុងរបាយការណ៍លទ្ធផលក្នុងទំព័រ ១៨ ។

### ក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងប្រតិបត្តិ

សមាជិករបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងប្រតិបត្តិនៅក្នុងអំឡុងពេលកាលបរិច្ឆេទរបស់របាយការណ៍ និងឆ្នាំនេះមានៈ

### ក្រុមប្រឹក្សាភិបាល

| | |
|---|---|
| លោក ពុង ឃាវសែ | ប្រធាន |
| លោកឧកញ៉ា លឹម ប៊ុនសួរ | អនុប្រធាន |
| លោក ម៉ុ វ៉ាន់ | សមាជិក |
| លោកជំទាវ អ៊ុក ម៉ាលី | សមាជិក |
| ឯកឧត្តម ហ៊្គី អានវ៉ានិថ | សមាជិក |
| លោកជំទាវ អ៊ឹង ប៊ូលីណា | សមាជិក |

### គណៈគ្រប់គ្រងប្រតិបត្តិ

| | |
|---|---|
| លោកជំទាវ អ៊ុក ម៉ាលី | អគ្គនាយក |
| ឯកឧត្តម ហ៊្គី អានវ៉ានិថ | អគ្គនាយករង |
| លោក ទឹម បូផល | អគ្គនាយករង |
| លោក ផង់ សំរេច | អគ្គនាយករង |

### របាយការណ៍របស់គណៈគ្រប់គ្រងប្រតិបត្តិ

គណៈគ្រប់គ្រងប្រតិបត្តិរបស់ធនាគារ ទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីផ្តល់ជូននូវទស្សនៈពិតប្រាកដ និងត្រឹមត្រូវរបស់ស្ថានភាពហិរញ្ញវត្ថុនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ហើយនិងលទ្ធផលប្រតិបត្តិការលំហូរសាច់ប្រាក់សំរាប់ចុងឆ្នាំដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ គណៈគ្រប់គ្រងប្រតិបត្តិតំរូវអោយមានៈ

១. ជ្រើសរើសគោលនយោបាយគណនេយ្យដែលសមស្របមកប្រើដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន បន្ទាប់ពីនោះអនុវត្តអោយបានជាប់លាប់ ។

២. អនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងប្រកាសរបស់ធនាគារកណ្តាល ឬបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិតប្រាកដ និងសមស្រប ការផ្លាស់ប្តូរទាំងនេះត្រូវបង្ហាញពន្យល់ និងកំណត់បរិមាណអោយបានច្បាស់លាស់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

៣. ថែរក្សាឯកសារគណនេយ្យ ហើយនិងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃ

# របាយការណ៍ហិរញ្ញវត្ថុ របស់ស្នងការគណនីឯករាជ្យឆ្នាំ ២០០៥

## របាយការណ៍របស់គណៈគ្រប់គ្រងប្រតិបត្តិ (ត)

ដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យក្នុងការសន្មតថា ធនាគារនឹងមិនបន្តកិច្ចប្រតិបត្តិការ អាជីវកម្មនៅពេលអនាគតដ៏ខ្លី ។

៥. ត្រួតពិនិត្យនិងដឹកនាំធនាគារដ៏មានប្រសិទ្ធិភាព និងចូលរួមរាល់ការសំរេចចិត្តសំខាន់ៗ ទាំងអស់ ដែលជះឥទ្ធិពលដល់ការធ្វើអាជីវកម្ម និងដំណើរការ ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុយ៉ាងត្រឹមត្រូវ ។

តាមយោបល់របស់គណៈគ្រប់គ្រងប្រតិបត្តិ មានហេតុផលមួយចំនួនដែលជឿថា ធនាគារនឹងអាចបង់សងប្រាក់បំណុលរបស់ខ្លួន នៅពេលដែលពួកគេដល់កាលកំណត់ដែលត្រូវសង ។

ជ.គណៈគ្រប់គ្រងប្រតិបត្តិ

លោកជំទាវ អ៊ុក ម៉ាលី
អគ្គនាយក

ឯកឧត្តម ហ៊ី អានវ៉ានិថ
អគ្គនាយករង
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦



PRICEWATERHOUSECOOPERS

PricewaterhouseCoopers (Cambodia) Ltd
124 Norodom Boulevard, Chamkarmon
Phnom Penh
Kingdom of Cambodia.
Tel : (855) 23 218 086
Fax : (855) 23 211 594

## របាយការណ៍របស់ស្នងការគណនីឯករាជ្យ ជូនចំពោះក្រុមប្រឹក្សាភិបាល និងភាគទុនិករបស់ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

យើងខ្ញុំបានធ្វើការត្រួតពិនិត្យ ទៅលើតារាងតុល្យការរបស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ហៅកាត់ថា ("ធនាគារ") នាការិយបរិច្ឆេទ ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ របាយការណ៍លទ្ធផល និងរបាយការណ៍លំហូរសាច់ប្រាក់ដែលពាក់ព័ន្ធ សំរាប់រយៈពេលនៃឆ្នាំដែលបានបញ្ចប់ទៅ ។ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់សំគាល់ទាំងនេះមានបង្ហាញ (នៅក្នុងទំព័រ ១៨ ដល់ទំព័រ ៤១ របាយការណ៍ហិរញ្ញវត្ថុ) ។ របាយការណ៍ហិរញ្ញវត្ថុនេះ គឺជាការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងធនាគារ ។ ការទទួលខុសត្រូវរបស់សវនករ គឺគ្រាន់តែបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើលទ្ធផលនៃ សវនកម្មរបស់យើងខ្ញុំ ។

របាយការណ៍រួមនិងយោបល់របស់យើងខ្ញុំ ត្រូវបានរៀបចំឡើងសំរាប់តែក្រុមប្រឹក្សាភិបាល និងភាគទុនិករបស់ធនាគារប៉ុណ្ណោះ មិនមែនសំរាប់គោលបំណងផ្សេងៗឡើយ ។ យើងមិនផ្តល់ជាយោបល់ ឬការទទួលខុសត្រូវចំពោះគោលបំណងផ្សេងណាមួយ ឬក៏បុគ្គលណាម្នាក់ដែលរបាយការណ៍នេះត្រូវបានបង្ហាញនៅក្នុងដៃ លើកលែងតែមានការបញ្ជាក់នូវការយល់ព្រមជាលាយលក្ខអក្សរអំពីសំណាក់យើងខ្ញុំ ។

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិ ហើយស្តង់ដារទាំងនោះ តំរូវអោយយើងធ្វើផែនការ និងបង្កើតនូវសវនកម្មមួយ ដើម្បីទទួលបានការធានាសមស្របថាតើរបាយការណ៍ហិរញ្ញវត្ថុមិនមានកំហុសធំដុំឡើយ ។ សវនកម្មនេះ រួមបញ្ចូលទាំងការត្រួតពិនិត្យទៅលើមូលដ្ឋានសាកល្បងភស្តុតាងបញ្ជាក់ពីចំនួនទឹកប្រាក់ និងការបង្ហាញជូននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការត្រួតពិនិត្យក៏រួមបញ្ចូលទាំងការវាយតំលៃនូវការប៉ាន់ប្រមាណសំខាន់ៗ និងការវិនិច្ឆ័យ ដែលធ្វើឡើងដោយគណៈគ្រប់គ្រងធនាគារក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងការវាយតំលៃ លើការបង្ហាញជាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុ ។ យើងខ្ញុំជឿជាក់ថា ការត្រួតពិនិត្យ របស់យើងខ្ញុំផ្តល់នូវមូលដ្ឋានសមហេតុផលសំរាប់យោបល់របស់យើងខ្ញុំ ។

រូបិយវត្ថុគោល និងរាយការណ៍របស់ធនាគារ បានផ្លាស់ប្តូរពីខ្មែររៀលទៅជាដុល្លារ សហរដ្ឋអាមេរិកនៅក្នុងឆ្នាំ ២០០៥ នេះ ។ សមតុល្យនីមួយៗនៃរបាយការណ៍ហិរញ្ញវត្ថុ ក្នុងឆ្នាំ២០០៥ ត្រូវបានប្តូរជាប្រាក់រៀល តាមអត្រាប្តូរប្រាក់ជាផ្លូវការ នាការិយបរិច្ឆេទរបស់ធនាគារកណ្តាល តាមប្រកាសលេខ ធ៧៩៥-១៣៥-ប្រក ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ១៩៩៥។ រូបិយវត្ថុគោល និងរាយការណ៍នៃរបាយការណ៍ហិរញ្ញវត្ថុក្នុងឆ្នាំ ២០០៤ គឺជាប្រាក់រៀល។ សមតុល្យប្រៀបធៀបនៃឆ្នាំ ២០០៤ ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានប្តូរជាប្រាក់ដុល្លារសហរដ្ឋអាមេរិក តាមអត្រាប្តូរប្រាក់ជាផ្លូវការនា ការិយបរិច្ឆេទ ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ហើយវាត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ សំរាប់គោលបំណងប្រៀបធៀបតែប៉ុណ្ណោះទេ។ សមតុល្យនៃឆ្នាំ ២០០៥ ដែលបានបង្ហាញជាប្រាក់រៀល និងសមតុល្យនៃឆ្នាំ ២០០៤ ដែលបានបង្ហាញជាប្រាក់ដុល្លារសហរដ្ឋអាមេរិក មិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យនេះ ហេតុនេះហើយយើងមិនបញ្ចេញយោបល់លើសមតុល្យទាំងនេះទេ។

**ជាយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញចាប់ពីទំព័រ ១៨ ដល់ ៤១ ផ្តល់នូវទស្សនៈពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាការិយបរិច្ឆេទ ៣១ ធ្នូ ២០០៥ និងលទ្ធផលនៃប្រតិបត្តិការ ព្រមទាំងរបាយការណ៍លំហូរសាច់ប្រាក់សំរាប់រយៈពេលដែលបានបញ្ចប់ ស្របទៅតាមតំរូវការរបស់ធនាគារកណ្តាល និងស្តង់ដារគណនេយ្យកម្ពុជា។**

Senaka Fernando
Authorised signatory
PRICEWATERHOUSECOOPERS (CAMBODIA) LIMITED
Date: 29 May 2006
Phnom Penh, Kingdom of Cambodia

# របាយការណ៍លទ្ធផល

## សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ៣១ ធ្នូ ២០០៥

| | | ចុងការិយបរិច្ឆេទ | | ចុងការិយបរិច្ឆេទ | |
|---|---|---|---|---|---|
| | កំណត់សំគាល់ | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
| ចំណូលការប្រាក់ | 3 | 6,390,896 | 5,605,455 | 26,279,363 | 22,573,166 |
| ចំណាយការប្រាក់ | 4 | (2,509,166) | (2,543,975) | (10,317,692) | (10,244,587) |
| **ចំណូលការប្រាក់សុទ្ធ** | | **3,881,730** | **3,061,480** | **15,961,671** | **12,328,579** |
| ចំណូលកំរៃ និងជើងសារ | 5 | 1,239,954 | 1,436,547 | 5,098,689 | 5,784,975 |
| ចំណាយកំរៃ និងជើងសារ | | (72,988) | (124,206) | (300,125) | (500,179) |
| **ចំណូលកំរៃនិងជើងសារសុទ្ធ** | | **1,166,966** | **1,312,341** | **4,798,564** | **5,284,796** |
| ចំណូលផ្សេងៗ (សុទ្ធ) | 6 | 242,597 | 550,183 | 997,559 | 2,215,587 |
| ចំណាយទូទៅ និងរដ្ឋបាល | 7 | (1,573,307) | (1,248,574) | (6,469,440) | (5,028,007) |
| ចំណេញប្រតិបត្តិការមុនការខាតបង់លើឥណទាន | | 3,717,986 | 3,675,430 | 15,288,354 | 14,800,955 |
| សំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទាន | 9 | (2,826,530) | (2,023,219) | (11,622,692) | (8,147,502) |
| សំវិធានធនសំរាប់ការប្រាក់បង្គរលើឥណទាន | 18 | - | (83,272) | - | (335,336) |
| ចំណេញសុទ្ធមុនបង់ពន្ធ | | 891,456 | 1,568,939 | 3,665,662 | 6,318,117 |
| ចំណាយពន្ធលើប្រាក់ចំណូល | 10 | (157,084) | (313,788) | (645,930) | (1,263,624) |
| ចំណេញសុទ្ធក្នុងឆ្នាំ | | 734,372 | 1,255,151 | 3,019,732 | 5,054,493 |

** បានត្រួតពិនិត្យជាប្រាក់រៀល*

លោកជំទាវ អ៊ុក ម៉ាលី
អគ្គនាយក
ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦

ឯកឧត្តម ហ៊ី អានវ៉ានិថ
អគ្គនាយករង

*កំណត់សំគាល់ដែលភ្ជាប់មកជាមួយពីទំព័រ ២២ ដល់ ៤១ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ*





# តារាងតុល្យការ

## សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ៣១ ធ្នូ ២០០៥

| | | ថ្ងៃទី ៣១ ធ្នូ | | ថ្ងៃទី ៣១ ធ្នូ | |
|---|---|---|---|---|---|
| | កំណត់សំគាល់ | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 គិតជាពាន់រៀល | 2004 គិតជាពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | | 6,215,685 | 6,218,433 | 25,558,895 | 25,041,629 |
| សមតុល្យនៅធនាគារកណ្ដាល (សុទ្ធ) | 11 | 47,840,388 | 74,790,897 | 196,719,676 | 301,182,942 |
| សមតុល្យជាមួយធនាគារដទៃ | 12 | 21,449,570 | 11,074,338 | 88,200,628 | 44,596,361 |
| ការបណ្ដាក់ទុនជាមួយធនាគារផ្សេងៗ | 13 | 41,461,053 | 9,551,978 | 170,487,852 | 38,465,817 |
| ការវិនិយោគជាមួយសញ្ញាប័ណ្ណរដ្ឋ និង ប័ណ្ណរតនាគារ | 14 | 13,587,178 | 21,762,680 | 55,870,477 | 87,638,314 |
| ឥណទាន និង បុរេប្រទានចំពោះអតិថិជន (សុទ្ធ) | 15 | 30,849,945 | 32,647,783 | 126,854,972 | 131,472,622 |
| ទ្រព្យសម្បត្តិនិងឧបករណ៍សំភារៈ | 16 | 283,582 | 336,893 | 1,166,091 | 1,356,669 |
| ផ្នែកទន់កុំព្យូទ័រ | 17 | 181,543 | 247,044 | 746,505 | 994,848 |
| ទ្រព្យសកម្មផ្សេងៗ (សុទ្ធ) | 18 | 1,635,754 | 3,217,044 | 6,726,221 | 12,955,037 |
| **សរុបទ្រព្យសកម្ម** | | **163,504,698** | **159,847,090** | **672,331,317** | **643,704,239** |
| **ទ្រព្យអកម្ម និងមូលនិធិភាគទុនិក** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | 19 | 732,783 | 936,814 | 3,013,202 | 3,772,550 |
| ប្រាក់បញ្ញើអតិថិជន | 20 | 142,895,476 | 139,267,224 | 587,586,196 | 560,829,112 |
| សំវិធានធនសំរាប់ពន្ធត្រូវបង់ | | 85,332 | 227,974 | 350,884 | 918,051 |
| ទ្រព្យអកម្មផ្សេងៗ | 21 | 1,023,107 | 948,087 | 4,207,019 | 3,817,953 |
| **សរុបទ្រព្យអកម្ម** | | **144,736,698** | **141,380,099** | **595,157,301** | **569,337,666** |
| **មូលនិធិភាគទុនិក** | | | | | |
| ដើមទុន | 22 | 12,159,533 | 12,416,191 | 50,000,000 | 50,000,000 |
| មូលធនបំរុង | 22 | 247,529 | 155,129 | 1,017,841 | 624,704 |
| ទុនបំរុងសំរាប់ហានិភ័យធនាគារ | 22 | 1,190,006 | 1,215,124 | 4,893,306 | 4,893,306 |
| ទុនបំរុងសំរាប់បំរែបំរួលអត្រាប្ដូរប្រាក់ | 22 | 3,504,660 | 3,578,634 | 14,411,160 | 14,411,160 |
| ទុនបំរុងទូទៅ | 22 | 174,692 | 125,662 | 718,335 | 506,041 |
| ចំណេញរក្សាទុក | | 1,491,580 | 976,251 | 6,133,374 | 3,931,362 |
| **សរុបមូលនិធិភាគទុនិក** | | **18,768,000** | **18,466,991** | **77,174,016** | **74,366,573** |
| **សរុបទ្រព្យអកម្ម និងមូលនិធិភាគទុនិក** | | **163,504,698** | **159,847,090** | **672,331,317** | **643,704,239** |

** បានត្រួតពិនិត្យជាប្រាក់រៀល*

លោកជំទាវ អ៊ុក ម៉ាលី
អគ្គនាយក
ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦

ឯកឧត្តម ហ៊ី អានវ៉ានិថ
អគ្គនាយករង

*កំណត់សំគាល់ដែលភ្ជាប់មកជាមួយពីទំព័រ ២២ ដល់ ៤១ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ*

# របាយការណ៍ស្តីពីការប្រែប្រួលនៅក្នុងមូលនិធិភាគទុនិក

សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ៣១ ធ្នូ ២០០៥

| | កំណត់សំគាល់ | ដើមទុន (US$) | មូលធនបំរុង (US$) | ទុនបំរុងសំរាប់ហានិភ័យធនាគារ (US$) | ទុនបំរុងសំរាប់បំរែបំរួលអត្រាប្តូរប្រាក់ (US$) | ទុនបំរុងទូទៅ (US$) | ប្រាក់ចំណេញរក្សាទុក (US$) | សរុប (US$) |
|---|---|---|---|---|---|---|---|---|
| **សមតុល្យនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៤** | | 12,575,453 | 110,288 | 1,230,711 | 3,342,060 | 101,986 | 468,304 | 17,828,802 |
| ចំណេញសុទ្ធក្នុងឆ្នាំ | | - | - | - | - | - | 1,255,151 | 1,255,151 |
| ការបែងចែកប្រាក់ចំណេញរក្សាទុក: | | | | | | | | |
| ការផ្ទេរទៅទុនបំរុងសំរាប់អត្រាប្តូរប្រាក់ | 22 | - | - | - | 278,900 | - | (278,900) | - |
| ការផ្ទេរទៅមូលធនបំរុង | 22 | - | 46,238 | - | - | - | (46,238) | - |
| ទុនបំរុងទូទៅ | 22 | - | - | - | - | 24,968 | (24,968) | - |
| ប្រាក់រង្វាន់បុគ្គលិក | | - | - | - | - | - | (20,807) | (20,807) |
| ប្រាក់លាភការក្រុមប្រឹក្សាភិបាល | | - | - | - | - | - | (4,161) | (4,161) |
| ភាគលាភផ្ទេរទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | - | - | - | - | - | (292,961) | (292,961) |
| ភាគលាភផ្ទេរទៅធនាគារជាតិ | | - | - | - | - | - | (73,240) | (73,240) |
| បំរែបំរួលនៃការប្តូររូបិយប័ណ្ណបរទេស | | (159,262) | (1,397) | (15,587) | (42,326) | (1,292) | (5,929) | (225,793) |
| **សមតុល្យនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ *** | | 12,416,191 | 155,129 | 1,215,124 | 3,578,634 | 125,662 | 976,251 | 18,466,991 |
| **ស្មើនឹងពាន់រៀល** | | 50,000,000 | 624,704 | 4,893,306 | 14,411,160 | 506,041 | 3,931,362 | 74,366,573 |
| **សមតុល្យនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥** | | 12,416,191 | 155,129 | 1,215,124 | 3,578,634 | 125,662 | 976,251 | 18,466,991 |
| ចំណេញសុទ្ធក្នុងឆ្នាំ | | - | - | - | - | - | 734,372 | 734,372 |
| ការបែងចែកប្រាក់ចំណេញរក្សាទុក: | | | | | | | | |
| ការផ្ទេរទៅទុនបំរុងសំរាប់អត្រាប្តូរប្រាក់ | | - | - | - | - | - | - | - |
| ការផ្ទេរទៅមូលធនបំរុង | | - | 95,607 | - | - | - | (95,607) | - |
| ទុនបំរុងទូទៅ | | - | - | - | - | 51,628 | (51,628) | - |
| ប្រាក់រង្វាន់បុគ្គលិក | | - | - | - | - | - | (43,023) | (43,023) |
| ប្រាក់លាភការក្រុមប្រឹក្សាភិបាល | | - | - | - | - | - | (8,604) | (8,604) |
| បំរែបំរួលនៃការប្តូររូបិយប័ណ្ណបរទេស | | (256,658) | (3,207) | (25,118) | (73,974) | (2,598) | (20,181) | (381,736) |
| **សមតុល្យនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥** | | 12,159,533 | 247,529 | 1,190,006 | 3,504,660 | 174,692 | 1,491,580 | 18,768,000 |
| **ស្មើនឹងពាន់រៀល** | | 50,000,000 | 1,017,841 | 4,893,306 | 14,411,160 | 718,335 | 6,133,374 | 77,174,016 |

** បានត្រួតពិនិត្យជាប្រាក់រៀល*

*កំណត់សំគាល់ដែលភ្ជាប់មកជាមួយពីទំព័រ ២២ ដល់ ៤១ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ*



ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

# របាយការណ៍លំហូរសាច់ប្រាក់

សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ៣១ ធ្នូ ២០០៥

| | កំណត់សំគាល់ | ចុងការិយបរិច្ឆេទ 2005 ដុល្លារអាមេរិក | ចុងការិយបរិច្ឆេទ 2004 ដុល្លារអាមេរិក* | ចុងការិយបរិច្ឆេទ 2005 ពាន់រៀល | ចុងការិយបរិច្ឆេទ 2004 ពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធ | | 891,456 | 1,568,939 | 3,665,662 | 6,318,117 |
| *និយ័តកម្មសំរាប់ :* | | | | | |
| សំវិធានធនសំរាប់ការខាតបង់លើឥណទាន និងបុរេប្រទាន | 9 | 4,804,267 | 2,867,410 | 19,755,144 | 11,547,061 |
| សំវិធានធនសំរាប់ការប្រាក់បង្គរបានទទួលលើឥណទាន និងបុរេប្រទាន | | - | 83,272 | - | 335,336 |
| រំលស់ | | 123,496 | 102,744 | 507,814 | 413,752 |
| ការខាតបង់លើការលក់ទ្រព្យសកម្មរូបី | | 440 | - | 1,810 | - |
| ចំណូលប្រតិបត្តិការមុនមានការប្រែប្រួលក្នុងមូលធនបង្វិល | | 5,819,659 | 4,622,365 | 23,980,430 | 18,614,266 |
| *ការប្រែប្រួលក្នុងមូលធនបង្វិល* | | | | | |
| ប្រាក់ឧបត្ថម្ភបុគ្គលិក និងក្រុមប្រឹក្សាភិបាល | | (51,628) | (24,968) | (212,294) | (100,547) |
| (ការកើនឡើង) សមតុល្យជាមួយ ធនាគារកណ្តាល | | - | (12,303) | - | (49,543) |
| ការកើនឡើងប្រាក់ឥណទាន និងបុរេប្រទានចំពោះអតិថិជន | | (3,681,297) | (4,627,597) | (15,137,495) | (18,635,335) |
| ការថយចុះទ្រព្យសកម្មផ្សេងៗ | | 1,514,790 | 1,015,118 | 6,228,815 | 4,087,882 |
| ការថយចុះប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | | (184,666) | (1,018,336) | (759,348) | (4,100,840) |
| ការកើនឡើងប្រាក់បញ្ញើអតិថិជន | | 6,507,073 | 11,029,598 | 26,757,085 | 44,416,191 |
| ការថយចុះទ្រព្យអកម្មផ្សេងៗ | | 115,825 | (395,872) | 476,273 | (1,594,177) |
| សាច់ប្រាក់សុទ្ធបានមកពី / (ប្រើក្នុង) ប្រតិបត្តិការ | | 10,039,756 | 10,588,005 | 41,283,466 | 42,637,897 |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | | (316,221) | (173,886) | (1,300,301) | (700,240) |
| សាច់ប្រាក់សុទ្ធបានមកពី / (ប្រើក្នុង) សកម្មភាពប្រតិបត្តិការ | | 9,723,535 | 10,414,119 | 39,983,165 | 41,937,657 |
| **លំហូរសាច់ប្រាក់បានមកពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់បញ្ញើបំរុងជាមួយធនាគារជាតិ | | (196,376) | (483,859) | (807,500) | (1,948,500) |
| ការបង់ប្រាក់សំរាប់ផ្នែកទន់កុំព្យូទ័រ | | - | (28,928) | - | (116,493) |
| ទិញទ្រព្យសម្បត្តិនិងឧបករណ៍សំភារៈ | | (17,194) | (16,552) | (70,701) | (66,656) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | (213,570) | (529,339) | (878,201) | (2,131,649) |
| **លំហូរសាច់ប្រាក់បានមកពីសកម្មភាព ហិរញ្ញប្បទាន** | | | | | |
| ផ្ទេរប្រាក់ភាគលាភទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | - | (292,961) | - | (1,179,754) |
| ផ្ទេរប្រាក់ភាគលាភទៅធនាគារជាតិ | | - | (73,240) | - | (294,938) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | | - | (366,201) | - | (1,474,692) |
| **ការកើនឡើង ជាសាច់ប្រាក់ និងសមមូលសាច់ប្រាក់** | | 9,509,962 | 9,518,579 | 39,104,964 | 38,331,316 |
| លំអៀងអត្រាប្តូរប្រាក់ | | (2,123,170) | - | - | - |
| **សាច់ប្រាក់ និង សមមូលសាច់ប្រាក់នៅដើមគ្រា** | | 102,711,453 | 93,192,874 | 413,619,020 | 375,287,704 |
| **សាច់ប្រាក់ និង សមមូលសាច់ប្រាក់នៅចុងគ្រា** | 24 | 110,098,245 | 102,711,453 | 452,723,984 | 413,619,020 |

** បានត្រួតពិនិត្យជាប្រាក់រៀល*

*កំណត់សំគាល់ដែលភ្ជាប់មកជាមួយពីទំព័រ ២២ ដល់ ៤១ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ*

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

# កំណត់សំគាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ៣១ ធ្នូ ២០០៥

## ១. ព័ត៌មានសាវតារ

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ("ធនាគារ") ត្រូវបានបង្កើតឡើងតាមអនុក្រិត្យលេខ ១២១៣ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៧៩ ក្នុងរបបរដ្ឋកម្ពុជា ។ ក្នុងឆ្នាំ ២០០០ ធនាគារបានផ្តាច់ចេញពីការគ្រប់គ្រងដោយផ្ទាល់ពីធនាគារជាតិ នៃកម្ពុជា ("ធនាគារកណ្តាល") ដើម្បីប្រែក្លាយខ្លួនទៅជាធនាគារពាណិជ្ជរបស់រដ្ឋ មានលក្ខណៈជាសហគ្រាសសេដ្ឋកិច្ចសាធារណៈ ហើយមានគោលដៅធ្វើប្រតិបត្តិការអាជីវកម្មស្វយ័ត ។ នៅពេលដែលការគ្រប់គ្រង និងប្រតិបត្តិការបច្ចេកទេសត្រូវបានពង្រឹង និងកែលំអដោយគណៈកម្មការកែទំរង់ធនាគារ នឹងមានលក្ខណៈសម្បត្តិស្មើនឹងធនាគារពាណិជ្ជដទៃទៀត ។

ក្នុងខែ មករា ឆ្នាំ ២០០១ ធនាគារបានទទួលអាជ្ញាប័ណ្ណពី ធនាគារជាតិនៃកម្ពុជា ដើម្បីប្រកបអាជីវកម្មជាធនាគារពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានរយៈពេលបី ឆ្នាំ ដោយចាប់ផ្តើមពីថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០០១ តទៅ។ នេះគឺជាអាជ្ញាប័ណ្ណលើកទី១ ដែលបានទទួលដើម្បីប្រកបអាជីវកម្ម ដោយមានការគ្រប់គ្រងផ្ទាល់ពីធនាគារជាតិនៃកម្ពុជា។ ថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០០៤ ធនាគារបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មលើកទី២ ពីធនាគារជាតិដែលមានសុពលភាព ៣ ឆ្នាំ មានប្រសិទ្ធិភាព ចាប់ពីថ្ងៃនេះតទៅ ។

នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ("ក្រ.សហវ") បានប្រកាសនូវរបាយការណ៍ ស្តីពីគោលបំណងធ្វើ ឯកជនភាវូបនីយកម្មរបស់ធនាគារ ដែលជាផ្នែកមួយនៃកម្មវិធីកំណែទំរង់វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ។ នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០៥ ភាគទុនិករបស់ធនាគារ ដែលតំណាងដោយគណៈកម្មាធិការ ឯកជនភាវូបនីយកម្ម បានចុះកិច្ចព្រមព្រៀងលក់ធនាគារ ជាមួយនឹងធនាគារកាណាឌីយ៉ា និងក្រុមហ៊ុន អាយអិនជី ហូលឌីង។ ធនាគារកណ្តាលបានលក់ភាគហ៊ុន ២០% របស់ខ្លួន និង ក្រ.សហវ បានបន្ថយភាគហ៊ុនរបស់ខ្លួនពីចំនួន ៨០% មក ១០% វិញ។ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦ លក្ខន្តិកៈរបស់ធនាគារត្រូវបានធ្វើវិសោធនកម្ម ដើម្បីឆ្លុះបង្ហាញពីការប្រែប្រួលភាគទុនិក។

បច្ចុប្បន្ន រាល់ប្រតិបត្តិការរបស់ធនាគារត្រូវបានគេធ្វើឡើងនៅទីស្នាក់ការកណ្តាល ដែលមានទីតាំងនៅអាគារលេខ ៣ វិថីក្រមួនស ភ្នំពេញ ។

នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ធនាគារមានបុគ្គលិកចំនួន ៩៤ នាក់ (២០០៤: ៩៣ នាក់) ។

## ២. សេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជូនដូចខាងក្រោម ។ គោលនយោបាយទាំងនេះ ត្រូវបានអនុវត្តយ៉ាងស៊ីសង្វាក់គ្នា និងយ៉ាងខ្ជាប់ខ្ជួនគ្រប់ការិយបរិច្ឆេទ ដែលបានបង្ហាញជូនទាំងអស់ លុះត្រាណាមានការបញ្ជាក់ប្រសិនបើមានការងាកចេញណាមួយ ។

### ២.១ មូលដ្ឋាននៃការបង្ហាញ

របាយការណ៍ហិរញ្ញវត្ថុនេះ រៀបចំឡើងស្របតាមបទបញ្ញត្តិរបស់ ធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ។ ការអនុវត្តនីស្តង់ដារគណនេយ្យកម្ពុជានេះ អាចខុសប្លែកពីគោលការណ៍គណនេយ្យជាទូទៅដែលអនុវត្តនៅក្នុងប្រទេសដទៃទៀត និងយុត្តាធិការ ផ្សេងទៀត។ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយ មិនសំដៅបង្ហាញស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការ ព្រមទាំងលំហូរសាច់ប្រាក់ ដោយស្របទៅតាមយុត្តាធិការផ្សេងក្រៅពីប្រទេសកម្ពុជា ។ ដូចនេះ របាយការណ៍ហិរញ្ញវត្ថុទាំងនេះ គឺត្រូវបានបង្ហាញសំដៅចំពោះតែអ្នកដែលត្រូវបានជូនដំណឹងអំពីបទបញ្ញត្តិរបស់ធនាគារកណ្តាល និងស្តង់ដារគណនេយ្យកម្ពុជា។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដោយប្រើប្រាស់អនុសញ្ញាតំលៃជាប្រវត្តិសាស្ត្រមួយ ។

### ២.២ រូបិយប័ណ្ណបរទេស

*ក) រូបិយវត្ថុគោល និងរាយការណ៍*

រាល់ធាតុនីមួយៗដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានវាស់វែងដោយប្រើរូបិយវត្ថុជាគោល ដែលធនាគារមានប្រតិបត្តិការអាជីវកម្មនៃបរិដ្ឋានសេដ្ឋកិច្ច ហៅថា ("រូបិយវត្ថុគោល")។ នៅក្នុងឆ្នាំ ២០០៤ រូបិយវត្ថុគោល គឺជាប្រាក់រៀល ប៉ុន្តែនៅក្នុងឆ្នាំ២០០៥នេះ រូបិយវត្ថុគោលគឺជាប្រាក់ដុល្លារសហរដ្ឋអាមេរិក ដោយសារធនាគារ ចាត់ទុកថាប្រាក់ដុល្លារសហរដ្ឋអាមេរិកមានលក្ខណៈល្អប្រសើរក្នុងការឆ្លុះបញ្ចាំងពីបរិដ្ឋានសេដ្ឋកិច្ចដែលជាមូលដ្ឋាននៃប្រតិបត្តិការនិងកាលៈទេសៈរបស់ធនាគារ ។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលត្រូវបានកំណត់ថាជារូបិយវត្ថុគោល និងរាយការណ៍ ។

*ខ) ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការដែលបានបង្ហាញ និងកំណត់ជាគោលថាជារូបិយប័ណ្ណក្រៅពីដុល្លារអាមេរិក ត្រូវបានប្តូរជាប្រាក់ដុល្លារអាមេរិក តាមអត្រាសមស្របរបស់ធនាគារ នាថ្ងៃនៃប្រតិបត្តិការនោះកើតឡើង ។ ចំណេញ ឬខាតពីការប្តូរប្រាក់ដែលកើតឡើងពីប្រតិបត្តិការខាងលើនេះ និងពីការប្តូរទ្រព្យសកម្ម និងទ្រព្យអកម្មរូបិយវត្ថុក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូល ។ អត្រាប្តូរប្រាក់ជាមធ្យមមិនត្រូវបានយកមកប្តូរប្រាក់ចំណូល និងចំណាយ ដែលកើតមាននៅក្នុងរបាយការណ៍លទ្ធផល ដោយមានអត្រាប្តូរប្រាក់មានស្ថេរភាព ពេញមួយឆ្នាំ ។

អត្រាប្តូរប្រាក់គោលប្រើសំរាប់ប្តូរទ្រព្យសកម្ម និងទ្រព្យអកម្មរូបិយវត្ថុនាការិយបរិច្ឆេទ តារាងតុល្យការ មានដូចខាងក្រោម :

| | ថ្ងៃទី ៣១ ធ្នូ 2005 | ថ្ងៃទី ៣១ ធ្នូ 2004 |
|---|---|---|
| ដុល្លារអាមេរិក | 4,112 | 4,027 |
| ផោនស្ទែរលីង | 7,092 | 7,526 |
| ហ្វ្រង់ | 554 | 534 |
| ហ្វ្រង់ស្វីស | 3,128 | 3,407 |
| ដឺមាក្ស | 1,861 | 1,776 |
| ថៃបាត | 100 | 101 |
| ដុល្លារកាណាដា | 3,533 | 3,216 |
| យ៉េនជប៉ុន (JPY) | 34 | 39 |
| អូស្ត្រាលីដុល្លារ | 3,011 | 2,936 |
| អឺរ៉ូ | 4,871 | 5,275 |

### ២.៣ ចំណូល និង ចំណាយការប្រាក់

ចំណូលការប្រាក់លើឥណទាន និងបុរេប្រទានទៅអោយអតិថិជន ប្រាក់បញ្ញើជាមួយធនាគារកណ្តាល និងធនាគារដទៃទៀត ហើយនិងការវិនិយោគជាមួយប័ណ្ណរតនាគារ ត្រូវបានគេទទួលស្គាល់លើមូលដ្ឋានបង្គរលើកលែង តែមានការសង្ស័យធ្ងន់ធ្ងរចំពោះ ការប្រមូលឥណទាន និងបុរេប្រទានអតិថិជន ដែលក្នុងករណីនេះគ្មានចំណូលការប្រាក់ ត្រូវបានគេទទួលស្គាល់ទេ។ គោលនយោបាយលើការព្យួរចំណូលការប្រាក់ ស្របទៅតាមគោលការណ៍របស់ធនាគារកណ្តាល ស្តីពីការព្យួរចំណូលការប្រាក់លើឥណទានមិនដំណើរការ និងសំវិធានធនសំរាប់បំណុលអាក្រក់ និងសង្ស័យ ។

ចំណាយការប្រាក់លើប្រាក់បញ្ញើអតិថិជន និងគណនីផាត់ទាត់នៃធនាគារដទៃទៀត ត្រូវបានគេទទួលស្គាល់ជាមូលដ្ឋានបង្គរ។

### ២.៤ ចំណូលកំរៃ និងជើងសារ

ចំណូលកំរៃនិងជើងសារត្រូវបានគេទទួលស្គាល់នៅពេលដែលប្រតិបត្តិការកើតឡើង ។ ចំណូលកំរៃ និងជើងសារបានទទួលពីការផ្ទេរប្រាក់ចេញ និងចូលកំរៃឈ្នួល លើដំណើរការឥណទាន កំរៃសក្ខីប័ត្រធានាការធ្វើពាណិជ្ជកម្ម ជាមួយលិខិតឥណទាន និងវិក័យប័ត្រទូទាត់។

### ២.៥ ឥណទាន និង បុរេប្រទានចំពោះអតិថិជន

ឥណទាន និងបុរេប្រទានចំពោះអតិថិជនទាំងអស់ ត្រូវបានរាយការណ៍នៅក្នុងតារាងតុល្យការ ដែលមានចំនួនទឹកប្រាក់ដើម ដកការកត់ត្រាជំរះបញ្ជី និងសំវិធានធនសំរាប់កូនបំណុលអាក្រក់ និងសង្ស័យ ។ ឥណទានរយៈពេលខ្លី គឺត្រូវទូទាត់សងវិញ ក្នុងរយៈពេលមួយឆ្នាំនៃកាលបរិច្ឆេទឥណទានដែលបានបុរេប្រទាន ។ ឥណទានរយៈពេលវែងជាឥណទានដែលការទូទាត់សងចុងក្រោយវិញ ច្រើនជាងមួយឆ្នាំនៃកាលបរិច្ឆេទឥណទាន ដែលបានបុរេប្រទាន ។

ឥណទានត្រូវបានគេកត់ត្រាជំរះបញ្ជី នៅពេលដែលមិនមានភាពជាក់លាក់លើការប្រមូលយកមកវិញ ។ ការប្រមូលយកមកវិញ នូវឥណទាន និងបុរេប្រទាន ដែលបានកត់ត្រាបញ្ចេញចោលពីមុនមក បានធ្វើអោយថយចុះចំនួនសំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទាននៅក្នុងរបាយការណ៍លទ្ធផល ។

### ២.៦ សំវិធានធនសំរាប់ការខាតបង់ឥណទាននិងបុរេប្រទាន

ធនាគារត្រូវអនុវត្តតាមសេចក្តីប្រកាសលេខធ៧-០២-១៤៥ ចុះថ្ងៃទី ៧ មិថុនា ២០០២ ស្តីពីចំណាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធន ដែលចេញផ្សាយដោយធនាគារកណ្តាល ។ សេចក្តីប្រកាសនេះ តំរូវអោយធនាគារពាណិជ្ជទាំងអស់ ធ្វើចំណាត់ថ្នាក់សំណុំឥណទានរបស់ពួកគេទៅតាម ៤ថ្នាក់ ហើយកំរិតសំវិធានធនជាក់លាក់ ត្រូវធ្វើឡើងដោយមិនគិតពីទ្រព្យសកម្ម (លើកលែងសាច់ប្រាក់) ដែលយកមកធ្វើជាទ្រព្យបញ្ចាំនោះទេ ។

កំរិតសំវិធានធនដែលបានកំណត់នៅក្នុងប្រកាសមានដូចខាងក្រោម:

| | |
|---|---|
| ស្តង់ដារ | 0% |
| ក្រោមស្តង់ដារ (ពី ៩១ ថ្ងៃ ដល់ ១៨០ថ្ងៃ) | ១0% |
| សង្ស័យ (ពី ១៨១ ថ្ងៃ ដល់ ៣៦០ថ្ងៃ) | ៣0% |
| បាត់បង់ (ច្រើនជាង ៣៦០ថ្ងៃ) | ១00% |

### ២.៧ ឥណទានហួសកាលកំណត់សង

ស្របទៅតាមសេចក្តីប្រកាស ធ៧០០-៥១ ចេញដោយធនាគារកណ្តាល ចុះថ្ងៃទី ១៧ កុម្ភៈ ២០០០ ប្រាក់ឥណទានហួសកាលកំណត់សង ត្រូវបានកំណត់ថាជាចំនួនប្រាក់ដើមសរុបដែលជំពាក់នៅពេលដែលប្រាក់ដើម ឬការប្រាក់នោះ បានហួសកាលកំណត់សង លើកលែងតែមានការកែប្រែការកំណត់សងនៃប្រាក់ការនិងប្រាក់ដើមនោះ។

### ២.៨ ការវិនិយោគក្នុងមូលប័ត្ររដ្ឋាភិបាល ប័ណ្ណរតនាគារ និងប្រាក់បញ្ញើ រយៈពេលខ្លី ជាមួយធនាគារផ្សេងៗ

ធនាគារបានធ្វើចំណាត់ថ្នាក់វិនិយោគទុនរបស់ខ្លួន លើមូលប័ត្ររដ្ឋាភិបាល ប័ណ្ណរតនាគារ ហើយនិងប្រាក់បញ្ញើ Overnight និងប្រាក់បញ្ញើរយៈពេលខ្លីជាមួយធនាគារដទៃផ្សេងទៀត ជាការវិនិយោគទុកដល់កាលវសានកំណត់ ដែលមានកាលវសានជាប់លាប់ ដែលធនាគារមានបំណង

និងលទ្ធភាពរក្សាទុករហូតដល់កាលវសានកំណត់។ ការវិនិយោគទុនទាំងនេះ ត្រូវបានកត់ត្រាតាមតំលៃដើមដែលបានដករំលស់ចេញពីសំវិធានធនណាមួយ។

**២.៩ ទ្រព្យសម្បត្តិនិងឧបករណ៍សំភារៈ**

ទ្រព្យសម្បត្តិ និងឧបករណ៍សំភារៈ ត្រូវបានរាយការណ៍តាមតំលៃដើមដករំលស់បង្គរទុកចេញ លើកលែងដី អាគារ ដែលមិនត្រូវបានគេដករំលស់ទេ ។ តំលៃដើមរាប់បញ្ចូលការចំណាយដែលជារបស់ផ្ទាល់ចំពោះការបានមកពីទ្រព្យសម្បត្តិ និងឧបករណ៍សំភារៈទាំងនោះ ។

តំលៃដើមលើកក្រោយ ត្រូវបានបញ្ចូលទៅក្នុងចំនួនទ្រព្យសកម្ម ឬទទួលស្គាល់ជាទ្រព្យសកម្មដោយឡែក កាលណាមានលទ្ធភាពផលប្រយោជន៍សេដ្ឋកិច្ចនៅពេលអនាគត ដែលបានបញ្ចូលជាមួយទ្រព្យសកម្ម និងបន្តទៅធនាគារ ហើយនិងថ្លៃដើមនៃទ្រព្យសកម្មនោះ អាចនឹងត្រូវបានគេវាស់វែងគួរអោយជឿបាន។ ការថែរក្សា និងការជួសជុល ត្រូវបានគេកត់ត្រាចូលទៅក្នុងរបាយការណ៍ចំណូល នៅពេលមានចំណាយកើតឡើង ។ ចំណាយលើការជួសជុល ត្រូវបានកត់ត្រាជាចំណាយដោយផ្ទាល់នៅក្នុងរបាយការណ៍ចំណូលនៅក្នុងឆ្នាំ ។

រំលស់ដែលបានគណនាដោយឡែកលើមូលដ្ឋានថេរ ដើម្បីកាត់បន្ថយថ្លៃដើមនៃទ្រព្យសកម្មទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វា មានដូចខាងក្រោមៈ

អត្រារំលស់មានដូចខាងក្រោម :

| | |
|---|---|
| សង្ហារឹម និងសំភារៈការិយាល័យ | ៣-៥ ឆ្នាំ |
| យានយន្ត | ៥ ឆ្នាំ |

ផលចំណេញ និងខាតបង់លើការលក់ គឺត្រូវបានកំណត់ឡើងដោយធ្វើការប្រៀបធៀប រវាងសាច់ប្រាក់ទទួលបានពីការលក់ និងតំលៃដើមសុទ្ធកត់ត្រា ។ ចំនួននេះ មានកត់ត្រានៅក្នុងរបាយការណ៍ចំណូល ។

**២.១០ ទ្រព្យសកម្មអរូបី**

អាជ្ញាប័ណ្ណកុំព្យូទ័រ Software ត្រូវបានគេប្រើលើមូលដ្ឋានតំលៃដើម ដែលកើតមានឡើងចំពោះផ្នែកទន់កុំព្យូទ័រជាក់លាក់ ដែលនាំមកនូវការប្រើប្រាស់។ តំលៃដើមទាំងនេះ ត្រូវបានគេធ្វើរំលស់សំរាប់រយៈពេល ៥ឆ្នាំ (២00៤: ១0ឆ្នាំ) ដើម្បីប្រើប្រាស់។

**២.១១ ប្រតិបត្តិការជួល**

ការជួលដែលការទទួលផល និងហានិភ័យនៃកម្មសិទ្ធិទ្រព្យសកម្ម នៅតែជារបស់ក្រុមហ៊ុនម្ចាស់កម្មសិទ្ធិនោះ ត្រូវបានគេរាប់បញ្ចូលថាជាប្រតិបត្តិការជួល។ ប្រាក់ជួលដែលបានបង់ក្រោមប្រតិបត្តិការជួល ត្រូវបានគេកត់ត្រាទៅក្នុងរបាយការណ៍លទ្ធផល ដោយឈរលើមូលដ្ឋានថេរ ក្នុងកំឡុងរយៈពេលនៃការជួលនោះ ។

**២.១២ ប្រាក់សោធននិវត្តរបស់បុគ្គលិក**

ធនាគារផ្តល់អោយនិយោជិតរបស់ខ្លួននូវប្រាក់ឧបត្ថម្ភពេលចូលនិវត្តន៍ ។ ប្រាក់ឧបត្ថម្ភនេះ គឺបានមកពីប្រភពដូចខាងក្រោមៈ

១. ការចូលរួមវិភាគទានប្រចាំខែ ដែលមានមូលដ្ឋានលើប្រាក់បៀវត្សរបស់បុគ្គលិក និងវិភាគទានផ្តល់ដោយធនាគារ និងបុគ្គលិកជាមួយអត្រា ៥% និង ៥% ជាបន្តបន្ទាប់ ។ វិភាគទាននេះគឺកត់ត្រាចូលទៅក្នុងរបាយការណ៍លទ្ធផល។

២. ធនាគារផ្តល់ការប្រាក់ លើសមតុល្យបង្គរនៃមូលនិធិសោធននិវត្តន៍ តាមអត្រា ៦% ក្នុងមួយឆ្នាំ ។ ការចូលរួមវិភាគទាននេះ គឺកត់ត្រាចូលទៅក្នុងរបាយការណ៍លទ្ធផល ។

មូលនិធិសោធននិវត្តន៍នឹងត្រូវទូទាត់អោយបុគ្គលិកទាំងអស់វិញ ចំពោះបុគ្គលិក ដែលបានចូលរួមចំណែកក្នុងមូលនិធិនេះ នៅពេលបញ្ចប់កិច្ចសន្យាការងារជាមួយធនាគារ ទោះបីជាក្នុងមូលហេតុណាក៏ដោយ ។

បន្ថែមលើសពីនេះទៅទៀត បុគ្គលិកម្នាក់ៗ នឹងទទួលនូវប្រាក់ឧបត្ថម្ភបន្ថែមទៀត ជាការបង់ប្រាក់សរុប ដែលស្មើនិងប្រាក់បៀវត្សដុលប្រចាំខែរបស់បុគ្គលិក គុណនឹងចំនួនទាបជាងនៃចំនួនការងារបំរើសេវាតិចជាង ឬ១0ឆ្នាំ នៅពេលបញ្ចប់កិច្ចសន្យាការងារជាមួយធនាគារ ។

**២.១៣ ពន្ធពន្យារពេលទូទាត់**

ពន្ធពន្យារពេលទូទាត់ត្រូវបានគេផ្តល់អោយទាំងស្រុងទៅលើវិសមភាពដែលកើតឡើង មូលដ្ឋានពន្ធនៃទ្រព្យសកម្ម ទ្រព្យអកម្ម និងចំនួនទឹកប្រាក់យោងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ពន្ធលើទ្រព្យសកម្មពន្យារពេលត្រូវគេទទួលស្គាល់នូវទំហំ ដែលពន្ធលើប្រាក់ចំណេញទៅអនាគត នឹងមានទប់ទល់ទៅនឹងវិសមភាពបណ្តោះអាសន្នអាចត្រូវបានគេប្រើប្រាស់ ។ វិសមភាពបណ្តោះអាសន្នកើតឡើងជាចំបងពីចំណេញ ឬខាតពីការប្តូររូបិយប័ណ្ណដែលមិនទទួលស្គាល់ ។

**២.១៤ ប្រតិបត្តិការសម្ព័ន្ធញាតិ**

អនុលោមទៅតាមច្បាប់ស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុភាគីសម្ព័ន្ធញាតិ ត្រូវបានកំណត់ជាភាគីដែលកាន់កាប់ផ្ទាល់ ឬដោយប្រយោល ១0% យ៉ាងតិចនៃមូលធន ឬសិទ្ធិបោះឆ្នោតនឹងរាប់បញ្ចូលបុគ្គលណាមួយ ដែលចូលរួមនៅក្នុងរដ្ឋបាល ការដឹកនាំ ការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

**២.១៥ សាច់ប្រាក់ និងសមមូលសាច់ប្រាក់**

សំរាប់គោលបំណងរបាយការណ៍លំហូរសាច់ប្រាក់ និងសមមូលសាច់ប្រាក់រួមមានសមតុល្យដែលមានកាលវសានតិចជាង ៩0ថ្ងៃពីពេលធ្វើលទ្ធកម្ម ។ សមតុល្យនេះ រួមបញ្ចូលទាំងសាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើមានកាលកំណត់ ហើយនិងគណនីផាត់ទាត់ នៅធនាគារជាតិ ប័ណ្ណរតនាគារ ដែលមានកាលវសានតិចជាង ឬស្មើ៣ខែ គណនីផាត់ទាត់ និងការបណ្តាក់ទុននៅធនាគារផ្សេងៗ ។

**២.១៦ ការបែងចែកប្រាក់ចំណេញ**

នៅក្នុងឆ្នាំ២00៥ អនុលោមទៅតាមគោលនយោបាយរបស់ធនាគារ គឺតំរូវអោយមាន :

១. បង្វែរ ៥%ទៅ ១0%នៃប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ ចូលក្នុងគណនីមូលធនបំរុង។
២. បង្វែរ ៦%នៃប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ បន្ទាប់ពីបង្វែរចូលគណនីមូលធនបំរុងចូលគណនីបំរុងទូទៅ ។
៣. បែងចែកប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ បន្ទាប់ពីបានបង្វែរចូលគណនីមូលធនបំរុង ចំនួន ៥% ទៅអោយបុគ្គលិក និង 0.៥% ទៅ ១% ទៅអោយសមាជិកក្រុមប្រឹក្សាភិបាល ។
៤. បែងចែកប្រាក់ចំណេញសុទ្ធក្នុងឆ្នាំដែលនៅសល់ ទៅអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិ នៃកម្ពុជា តាមភាគរយនៃភាគហ៊ុន ។

ប្រាក់បែងចែកប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ ត្រូវបានប្រកាស និងអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងត្រូវបានកត់ដោយផ្ទាល់ពីគណនីប្រាក់ចំណេញរក្សាទុក ។
អនុលោមទៅតាមវិសោធនកម្មនៃលក្ខន្តិកៈរបស់ធនាគារ ប្រាក់ចំណេញប្រចាំឆ្នាំរបស់ធនាគារ និងកត់ត្រាចូលទៅក្នុងគណនីចំណេញរក្សាទុកតែមួយគត់ ។ ធនាគារនឹងមិនធ្វើការបែងចែកប្រាក់ចំណេញ និងផ្ទេរទៅក្នុងគណនីបំរុង និងទុនបំរុងទូទៅនោះឡើយ ។

# កំណត់សំគាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ (ត)

## ៣. ចំណូលការប្រាក់

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ឥណទាននិង បុរេប្រទានទៅអោយអតិថិជន | 3,635,457 | 3,790,517 | 14,949,001 | 15,264,411 |
| ប័ណ្ណរតនាគារ | 508,618 | 698,867 | 2,091,437 | 2,814,336 |
| ធនាគារកណ្ដាល | 1,116,308 | 687,824 | 4,590,258 | 2,769,866 |
| មូលប័ត្ររដ្ឋាភិបាល | 267,510 | 297,989 | 1,100,000 | 1,200,000 |
| ធនាគារក្រៅប្រទេស | 863,003 | 130,258 | 3,548,667 | 524,553 |
| **សរុប** | **6,390,896** | **5,605,455** | **26,279,363** | **22,573,166** |

## ៤. ចំណាយការប្រាក់

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ប្រាក់បញ្ញើមានកាលកំណត់ | | | | |
| ដុល្លារអាមេរិក | 1,479,309 | 1,540,549 | 6,082,917 | 6,203,791 |
| រៀល | 596,026 | 580,957 | 2,450,860 | 2,339,512 |
| ប្រាក់បញ្ញើសន្សំ | | | | |
| ដុល្លារអាមេរិក | 276,704 | 266,930 | 1,137,805 | 1,074,928 |
| រៀល | 138,597 | 135,594 | 569,916 | 546,039 |
| មូលនិធិសោធននិវត្តន៍ | 18,530 | 19,945 | 76,194 | 80,317 |
| **សរុប** | **2,509,166** | **2,543,975** | **10,317,692** | **10,244,587** |

## ៥. ចំណូលកំរៃនិងជើងសារ

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| កំរៃលើការផ្ទេរប្រាក់ | 490,029 | 486,254 | 2,015,000 | 1,958,146 |
| កំរៃជើងសារពីដំណើរការឥណទាន | 298,660 | 474,386 | 1,228,088 | 1,910,352 |
| កំរៃជើងសារពីលិខិតឥណទាននិងប័ណ្ណធានា | 196,659 | 192,721 | 808,662 | 776,089 |
| កំរៃ SWIFT | 151,460 | 149,837 | 622,804 | 603,390 |
| កំរៃផ្សេងៗ | 103,146 | 133,349 | 424,135 | 536,998 |
| **សរុប** | **1,239,954** | **1,436,547** | **5,098,689** | **5,784,975** |

## ៦. ចំណូលផ្សេងៗ (សុទ្ធ)

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ចំណេញ/(ខាត) លើការប្ដូរប្រាក់ | (14,955) | 271,283 | (61,493) | 1,092,455 |
| ចំណេញលើការវាយតំលៃឡើងវិញ (សុទ្ធ) | 167,103 | 278,900 | 687,127 | 1,123,132 |
| ចំណូលផ្សេងៗ | 90,449 | - | 371,925 | - |
| **សរុប** | **242,597** | **550,183** | **997,559** | **2,215,587** |

*បានត្រួតពិនិត្យជាប្រាក់រៀល*

## ៧. ចំណាយទូទៅ និងរដ្ឋបាល

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ចំណាយបុគ្គលិក (មើលកំណត់សំគាល់ ៨) | 606,341 | 519,868 | 2,493,276 | 2,093,507 |
| ថ្លៃឈ្នួលតុលាការ និងច្បាប់ | 245,274 | 96,137 | 1,008,567 | 387,142 |
| ចំណាយទំនាក់ទំនង | 71,733 | 55,805 | 294,967 | 224,725 |
| រំលស់ | 123,496 | 102,744 | 507,814 | 413,752 |
| ចំណាយលើការជួល | 74,400 | 64,800 | 305,933 | 260,950 |
| ចំណាយទឹក ភ្លើង និងការិយាល័យ | 72,077 | 82,623 | 296,379 | 332,722 |
| ចំណាយទីផ្សារ (Marketing) | 66,051 | 47,303 | 271,603 | 190,488 |
| កំរៃផ្ញើជូនធនាគារកណ្ដាលលើការផ្ទេរភាគហ៊ុន | 59,582 | - | 245,000 | - |
| ចំណាយធានារ៉ាប់រង និងសន្តិសុខ | 44,466 | 44,490 | 182,843 | 179,161 |
| ចំណាយសវនកម្ម | 21,400 | 29,750 | 87,997 | 119,802 |
| ចំណាយប្រជុំរបស់ក្រុមប្រឹក្សាភិបាល | 23,739 | 24,882 | 97,615 | 100,200 |
| ថ្លៃដឹកជញ្ជូន | 22,660 | 13,147 | 93,179 | 52,943 |
| ជួសជុល និងថែរក្សា | 17,120 | 12,252 | 70,399 | 49,340 |
| ចំណាយផ្សេងៗ | 124,968 | 154,773 | 513,868 | 623,275 |
| **សរុប** | **1,573,307** | **1,248,574** | **6,469,440** | **5,028,007** |

## ៨. ចំណាយបុគ្គលិក

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| បៀវត្ស | 469,857 | 416,805 | 1,932,054 | 1,678,472 |
| ប្រាក់ឧបត្ថម្ភនិងចំណាយប្រចាំថ្ងៃ | 117,804 | 86,545 | 484,411 | 348,516 |
| ការផ្ដល់មូលនិធិសោធននិវត្តន៍ | 18,680 | 16,518 | 76,811 | 66,519 |
| **សរុប** | **606,341** | **519,868** | **2,493,276** | **2,093,507** |

## ៩. សំវិធានធនសំរាប់ការខាតបង់ឥណទាននិងបុរេប្រទាន

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| សំវិធានធនសំរាប់ការខាតបង់ឥណទាននិងបុរេប្រទាន (កំណត់សំគាល់ ១៥ ង) | (4,804,267) | (2,867,410) | (19,755,144) | (11,547,061) |
| ការប្រមូលបានវិញនូវឥណទានអាក្រក់ដែល កាត់ចេញពីបញ្ជីពីមុន | 1,433,447 | 302,547 | 5,894,330 | 1,218,358 |
| ការប្រមូលបានវិញនូវនៃឥណទានដែលបានធ្វើសំវិធានធន (កំណត់សំគាល់ ១៥ ង) | 544,290 | 541,644 | 2,238,122 | 2,181,201 |
| **សរុប** | **(2,826,530)** | **(2,023,219)** | **(11,622,692)** | **(8,147,502)** |

## ១០. ពន្ធ

### ក) ចំណាយពន្ធលើប្រាក់ចំណូល

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ពន្ធក្នុងឆ្នាំ | 178,291 | 303,893 | 733,132 | 1,223,775 |
| សកម្មភាពពន្ធពន្យារទុក | (21,207) | 9,895 | (87,202) | 39,849 |
| **សរុប** | **157,084** | **313,788** | **645,930** | **1,263,624** |

*បានត្រួតពិនិត្យជាប្រាក់រៀល*

## កំណត់សំគាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ (ត)

| ខ) ការផ្ទៀងផ្ទាត់ចំណាយពន្ធលើប្រាក់ចំណូល និងចំណេញគណនេយ្យ | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ចំណេញគណនេយ្យមុនបង់ពន្ធ | 891,455 | 1,568,939 | 3,665,662 | 6,318,117 |
| ពន្ធតាមអត្រា ២០% | 178,291 | 313,788 | 733,132 | 1,263,624 |
| *បូកបន្ថែម/(កាត់ចេញ)* | | | | |
| ចំណេញសុទ្ធបានមកពីការប្តូររូបិយប័ណ្ណបរទេស មិនទទួលស្គាល់ក្នុងឆ្នាំ (មើលកំណត់សំគាល់ ៦) | 33,420 | 55,780 | 137,425 | 224,627 |
| ចំណេញសុទ្ធបានមកពីការប្តូររូបិយប័ណ្ណ បរទេសមិនទទួលស្គាល់ក្នុងឆ្នាំមុន ដែលត្រូវបានទទួលស្គាល់ក្នុងឆ្នាំ (មើលកំណត់សំគាល់ ៦) | (54,627) | (45,885) | (224,627) | (184,778) |
| **សរុបចំណាយពន្ធលើប្រាក់ចំណូល** | **157,084** | **303,893** | **645,930** | **1,223,775** |

### គ) ពន្ធពន្យារ

ការផ្លាស់ប្តូរនៃពន្ធពន្យារ គឺជាលទ្ធផលចំបងកើតពីឥទ្ធិពលនៃពន្ធលើប្រាក់ចំណេញ ដែលកើតឡើងពី ការមិនទទួលស្គាល់ចំណេញខាតនៃការប្តូររូបិយប័ណ្ណបរទេស។

### ឃ) បញ្ហាពន្ធផ្សេងៗ

ពន្ធលើប្រាក់ចំណូលរបស់ធនាគារ គឺជាប្រធានបទដែលត្រូវបានពិនិត្យដោយនាយកដ្ឋានពន្ធដារ។ ផ្នែកខ្លះនៃច្បាប់ពន្ធហើយនិងសារាចរអាចបើកចំហចំពោះការបកស្រាយខុសគ្នា ដូច្នេះចំនួនទឹកប្រាក់ដែលជាប់ពន្ធ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ អាចត្រូវបានផ្លាស់ប្តូរនៅកាលបរិច្ឆេទលើកក្រោយ យោលទៅលើការសំរេចចិត្តដោយ នាយកដ្ឋានពន្ធដារ។

## ១១. សមតុល្យនៅធនាគារកណ្តាល

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ប្រាក់បញ្ញើមានកាលកំណត់ | 25,100,000 | 58,600,000 | 103,211,200 | 235,982,200 |
| គណនីទុនបំរុងកាតព្វកិច្ច | 9,500,000 | 9,500,000 | 39,064,000 | 38,256,500 |
| គណនីចរន្ត | 12,012,386 | 5,436,975 | 49,394,933 | 21,894,699 |
| ប្រាក់បញ្ញើតាមច្បាប់ | 1,215,953 | 1,241,619 | 5,000,000 | 5,000,000 |
| ប្រាក់ត្រូវទារពីធនាគារជាតិ | 140,578 | 143,545 | 578,056 | 578,056 |
| | 47,968,917 | 74,922,139 | 197,248,189 | 301,711,455 |
| សំវិធានធនសំរាប់ការខាតបង់លើប្រាក់ត្រូវទារពីធនាគារកណ្តាល | (128,529) | (131,242) | (528,513) | (528,513) |
| **សរុប** | **47,840,388** | **74,790,897** | **196,719,676** | **301,182,942** |

គណនីទុនបំរុងកាតព្វកិច្ចគ្មានការប្រាក់តំណាងអោយទុនបំរុងអប្បបរមាដែលគណនាតាមអត្រា ៨% នៃសមតុល្យបញ្ញើរបស់អតិថិជន និងគណនីផាត់ទាត់របស់ធនាគារផ្សេងៗ ។ ក្នុងការគណនាប្រាក់បំរុងកាតព្វកិច្ច ធនាគារកណ្តាលបានអនុញ្ញាតអោយដកចេញសមតុល្យជាប្រាក់រៀល ដែលធនាគារមានចំនួន ១០.៤៧៣.៥០៨ ពាន់រៀល នាកាលបរិច្ឆេទ ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ (ឆ្នាំ២០០៤ មានចំនួន ១០.៦៣៦.១១៣ពាន់រៀល) ពីប្រាក់បំរុងកាតព្វកិច្ច ។

អនុលោមតាមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា លេខ ធ ៧០០-០៤ ធនាគារត្រូវតំកល់ទឹកប្រាក់បញ្ញើតាមច្បាប់ នៅធនាគារជាតិស្មើនឹង ៥.០០០.០០០ពាន់រៀល ដែលតំណាងអោយ ១០%នៃដើមទុនចុះបញ្ជី។ អនុលោមតាមប្រកាសរបស់ធនាគារ នៃកម្ពុជា លេខ ធ-៧០១-១៣៦-របក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០០១ ប្រាក់បញ្ញើតាមច្បាប់ត្រូវទទួលបានការប្រាក់តាមអត្រាហិរញ្ញប្បទានជាមធ្យម ៣% ចាប់ពីឆ្នាំ២០០២ ។ ប្រាក់តំកល់នេះនឹងត្រូវសងត្រលប់វិញតែនៅពេលដែលធនាគារឈប់ធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ប៉ុណ្ណោះ ។

ប្រាក់ដែលធនាគារកណ្តាលជំពាក់ គឺជាប្រាក់បុរេប្រទានដែលបានផ្តល់ទៅអោយធនាគារកណ្តាល មុនពេលដែលធនាគារក្លាយទៅជាធនាគារឯករាជ្យពីការគ្រប់គ្រងផ្ទាល់របស់ធនាគារ កណ្តាល ។ សមតុល្យដែលធនាគារ កណ្តាលជំពាក់ទាំងអស់ ត្រូវបានធ្វើសំវិធានធននាការិយបរិច្ឆេទ ដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥។

** បានត្រួតពិនិត្យជាប្រាក់រៀល*



| អត្រាការប្រាក់ប្រចាំឆ្នាំលើសមតុល្យជាមួយធនាគារកណ្តាល ត្រូវបានសង្ខេបដូចខាងក្រោម: | 2005 | 2004 |
|---|---|---|
| ប្រាក់បញ្ញើរយៈពេលខ្លី | 1.80% - 3.28% | 0.8% - 1.8% |
| ប្រាក់បញ្ញើបំរុងកាតព្វកិច្ច | 0% | 0% |
| គណនីចរន្ត | 0% | 0% |
| ប្រាក់បញ្ញើតាមច្បាប់ | 1.04% - 1.39% | 3% |

## ១២. សមតុល្យជាមួយធនាគារផ្សេងៗ

សមតុល្យជាមួយធនាគារផ្សេងៗ ជាគណនីចរន្តជាមួយធនាគារដទៃនៅក្រៅប្រទេសកម្ពុជា។ គណនីចរន្តនេះបាន ទទួលការប្រាក់តាមអត្រាប្រចាំឆ្នាំ ចាប់ពី ១.៣% ទៅដល់ ២.០% នៅក្នុងឆ្នាំ ២០០៥ (២០០៤: ០% ទៅដល់ ១.២%)។

## ១៣. ការបណ្តាក់ទុននៅធនាគារផ្សេងៗ

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ការបណ្តាក់ទុន Overnight ជាមួយធនាគារ ផ្សេងៗ | 23,114,413 | 6,466,339 | 95,046,465 | 26,039,948 |
| ការបណ្តាក់ទុនរយៈពេលខ្លីជាមួយ ធនាគារផ្សេងៗ | 18,346,640 | 3,085,639 | 75,441,387 | 12,425,869 |
| **សរុប** | **41,461,053** | **9,551,978** | **170,487,852** | **38,465,817** |

| អត្រាការប្រាក់ប្រចាំឆ្នាំបានមកពីការបណ្តាក់ទុនជាមួយនិងធនាគារផ្សេងៗមានសង្ខេបដូចខាងក្រោម: | 2005 | 2004 |
|---|---|---|
| ការបណ្តាក់ទុន Overnight ជាមួយធនាគារ ផ្សេងៗ | 1.40%-3.60% | 0.08%-1.59% |
| ការបណ្តាក់ទុនរយៈពេលខ្លីជាមួយ ធនាគារផ្សេងៗ | 0.24%-4.28% | 0.88%-2.18% |

## ១៤. ការវិនិយោគទុនជាមួយមូលប័ត្ររដ្ឋាភិបាល និងប័ណ្ណរតនាគារ

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| មូលប័ត្ររដ្ឋាភិបាល (កំណត់សំគាល់ ២២) | 9,727,626 | 9,932,952 | 40,000,000 | 40,000,000 |
| ប័ណ្ណរតនាគារ | 3,859,552 | 11,829,728 | 15,870,477 | 47,638,314 |
| **សរុប** | **13,587,178** | **21,762,680** | **55,870,477** | **87,638,314** |

ប័ណ្ណរតនាគារ នៅថ្ងៃទី ៣១ ធ្នូ ២០០៥ ជាប័ណ្ណបញ្ចុះថ្លៃ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានរយៈកាលកំណត់បីខែ និងបានទទួលចំណូលការប្រាក់ ៦% ក្នុងមួយឆ្នាំ ។

## ១៥. ឥណទាន និងបុរេប្រទានចំពោះអតិថិជន

| ក. ការវិភាគតាមប្រភេទនៃឥណទាន | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ឥណទានពាណិជ្ជកម្ម: | | | | |
| ឥណទានរយៈពេលខ្លី | 4,103,000 | 621,932 | 16,871,536 | 2,504,519 |
| ឥណទានរយៈពេលយូរ | 8,019,102 | 8,835,463 | 32,974,547 | 35,580,408 |
| ឥណទានវិបារូបន៏ | 21,591,622 | 27,424,615 | 88,784,749 | 110,438,924 |
| ឥណទានប្រើប្រាស់: ឥណទានឯកត្តជន | 30,000 | 325,288 | 123,360 | 1,309,939 |
| | 33,743,724 | 37,207,298 | 138,754,192 | 149,833,790 |
| សំវិធានធនសំរាប់ការខាតបង់លើឥណទាននិងបុរេប្រទាន | (2,893,779) | (4,559,515) | (11,899,220) | (18,361,168) |
| **សរុប** | **30,849,945** | **32,647,783** | **126,854,972** | **131,472,622** |

រាល់ឥណទានមានកាលកំណត់ទាំងអស់ត្រូវបានគេផ្តល់អោយជនជាតិកម្ពុជា។ ឥណទាន និងបុរេប្រទាន ភាគច្រើនផ្តល់ទៅអោយអតិថិជនគឺមានវត្ថុដាក់ធានា។

** បានត្រួតពិនិត្យជាប្រាក់រៀល*

## កំណត់សំគាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ (ត)

| ខ. ការវិភាគតាមប្រភេទឧស្សាហកម្ម | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| សេវាកម្ម | 22,519,230 | 22,864,349 | 92,599,074 | 92,074,733 |
| ការនាំចូលនិងនាំចេញ | 2,245,675 | 5,249,871 | 9,234,214 | 21,141,231 |
| លក់ដុំ និងលក់រាយ | 2,895,710 | 3,162,897 | 11,907,161 | 12,736,986 |
| កសិកម្ម | 2,682,811 | 2,924,884 | 11,031,717 | 11,778,510 |
| ការឧបត្ថម្ភជាតិគីមី និងថ្នាំពេទ្យ | 1,821,298 | 2,163,391 | 7,489,178 | 8,711,974 |
| ឧស្សាហកម្មផ្សេងៗ | 1,441,685 | 719,343 | 5,928,210 | 2,896,796 |
| ឯកត្តជន | 137,315 | 122,563 | 564,638 | 493,560 |
| | **33,743,724** | **37,207,298** | **138,754,192** | **149,833,790** |
| សំវិធានធនសំរាប់ការខាតបង់លើឥណទាននិងបុរេប្រទាន | (2,893,779) | (4,559,515) | (11,899,220) | (18,361,168) |
| **សរុប** | **30,849,945** | **32,647,783** | **126,854,972** | **131,472,622** |

| គ. ការវិភាគតាមការធានា | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| មានការធានា | 33,743,724 | 37,167,649 | 138,754,192 | 149,674,123 |
| ពុំមានការធានា | - | 39,649 | - | 159,667 |
| | 33,743,724 | 37,207,298 | 138,754,192 | 149,833,790 |
| សំវិធានធនសំរាប់ការខាតបង់លើឥណទាននិងបុរេប្រទាន | (2,893,779) | (4,559,515) | (11,899,220) | (18,361,168) |
| **សរុប** | **30,849,945** | **32,647,783** | **126,854,972** | **131,472,622** |

| ឃ. ការវិភាគតាមចំណាត់ថ្នាក់ | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| បទដ្ឋាន | 24,889,702 | 21,726,510 | 102,346,454 | 87,492,656 |
| ក្រោមបទដ្ឋាន | 1,004,708 | 4,075,364 | 4,131,359 | 16,411,492 |
| សង្ស័យ | 7,849,314 | 2,853,883 | 32,276,379 | 11,492,588 |
| បាត់បង់ | - | 8,551,541 | - | 34,437,054 |
| | 33,743,724 | 37,207,298 | 138,754,192 | 149,833,790 |
| សំវិធានធនសំរាប់ការខាតបង់លើឥណទាននិងបុរេប្រទាន | (2,893,779) | (4,559,515) | (11,899,220) | (18,361,168) |
| **សរុប** | **30,849,945** | **32,647,783** | **126,854,972** | **131,472,622** |

| ង. សំវិធានធនសំរាប់ការខាតបង់លើឥណទាននិងបុរេប្រទាន | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ចលនាសំវិធានធនសំរាប់ការខាតបង់លើឥណទាននិងបុរេប្រទានមានដូចតទៅ: | | | | |
| សមតុល្យដើមគ្រា | 4,465,265 | 4,024,919 | 18,361,168 | 16,208,348 |
| សំវិធានធនក្នុងឆ្នាំ | 4,804,267 | 2,867,410 | 19,755,144 | 11,547,061 |
| បំណុលអាក្រក់ដែលបានកាត់ចេញពីបញ្ជី | (6,008,984) | (1,836,758) | (24,708,943) | (7,396,625) |
| បំណុលអាក្រក់ដែលប្រមូលមកវិញ | (544,290) | (541,644) | (2,238,122) | (2,181,201) |
| លំអៀងអត្រាប្តូររូបិយប័ណ្ណ | 177,521 | 45,588 | 729,973 | 183,585 |
| **សរុប** | **2,893,779** | **4,559,515** | **11,899,220** | **18,361,168** |

* បានត្រួតពិនិត្យជាប្រាក់រៀល

នៅក្នុងឆ្នាំ ២០០៥ ក្រុមប្រឹក្សាភិបាលបានសំរេចកាត់ចេញពីបញ្ជី នូវឥណទានអាក្រក់ដែល មានចំនួន ៦,០០៨,៨៤៤ ដុល្លារអាមេរិក (ឆ្នាំ ២០០៤: ១,៨៣៦,៧៥៨ ដុល្លារអាមេរិក)។ ឥណទានអាក្រក់ដែលបានជំរះបញ្ជី ត្រូវបានធានាដោយអចលនទ្រព្យដែលមានការវាយតំលៃពីខាងក្រៅថាមានតំលៃ ១៤,៣២៩,៧២០ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៥ (២០០៤: ៧,១៦៦,៣១៥ ដុល្លារអាមេរិក)។ ទ្រព្យសម្បត្តិទាំងនេះ មិនត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មរបស់ធនាគារទេ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ រហូតដល់ពេលនីតិវិធី រឹបអូសកើតមានឡើង។

### ច. អត្រាការប្រាក់

| ឥណទាននិងបុរេប្រទានទៅអោយអតិថិជនទាំងនេះ ទទួលបានការប្រាក់តាមអត្រាប្រចាំឆ្នាំមានដូចខាង ក្រោម : | 2005 | 2004 |
|---|---|---|
| ឥណទាននិងបុរេប្រទានជាប្រាក់រៀល | 10.4% - 16.8% | 10.4% - 16.8% |
| ឥណទាននិងបុរេប្រទានជាប្រាក់ដុល្លារអាមេរិក | 10.0% - 36.0% | 12.0% - 36.0% |

| ១៦. ទ្រព្យសម្បត្តិ និងឧបករណ៍សំភារៈ | ដីធ្លី ដុល្លារអាមេរិក | អាគារ ដុល្លារអាមេរិក | សង្ហារឹម និងសំភារៈ ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|
| *១ មករា ២០០៤* | | | | | |
| តំលៃដើម | 227,313 | 65,016 | 335,492 | 54,023 | 681,845 |
| រំលស់បង្គរ | - | - | (247,168) | (47,093) | (294,261) |
| **ចំនួនចុះបញ្ជីសុទ្ធ** | **227,313** | **65,016** | **88,324** | **6,930** | **387,584** |
| **ចុងការិយបរិច្ឆេទ ៣១ ធ្នូ ២០០៤** | | | | | |
| ចំនួនចុះបញ្ជីសុទ្ធដើមគ្រា | 227,313 | 65,016 | 88,325 | 6,930 | 287,584 |
| លំអៀងការប្តូរប្រាក់ | (2,879) | (823) | (1,119) | (88) | (4,909) |
| បូកបន្ថែម | - | - | 16,552 | - | 16,552 |
| រំលស់បន្ទុក | - | - | (55,492) | (6,842) | (62,334) |
| **ចំនួនចុះបញ្ជីសុទ្ធចុងគ្រា** | **224,434** | **64,193** | **48,266** | **-** | **336,893** |
| **៣១ ធ្នូ ២០០៤** | | | | | |
| តំលៃដើម | 224,434 | 64,192 | 328,379 | 53,339 | 670,345 |
| រំលស់បង្គរ | - | - | (280,113) | (53,339) | (333,452) |
| **ចំនួនចុះបញ្ជីសុទ្ធ** | **224,434** | **64,192** | **48,266** | **-** | **336,893** |
| **ស្មើនិងពាន់រៀល** | **903,797** | **258,503** | **194,369** | **-** | **1,356,669** |
| **ចុងការិយបរិច្ឆេទ ៣១ ធ្នូ ២០០៥** | | | | | |
| ចំនួនចុះបញ្ជីសុទ្ធដើមគ្រា | 224,434 | 64,192 | 48,266 | - | 336,892 |
| វិសមភាពនៃការប្តូរប្រាក់ | (4,639) | (1,326) | 3,606 | - | (2,359) |
| បូកបន្ថែម | - | - | 17,194 | - | 17,194 |
| លក់ឬបោះចោល | - | - | (440) | - | (440) |
| រំលស់បន្ទុក | - | - | (67,705) | - | (67,705) |
| ចំនួនចុះបញ្ជីសុទ្ធចុងគ្រា | **219,795** | **62,866** | **921** | **-** | **283,582** |
| **៣១ ធ្នូ ២០០៥** | | | | | |
| តំលៃដើម | 219,795 | 62,866 | 329,479 | 52,236 | 664,376 |
| រំលស់បង្គរ | - | - | (328,558) | (52,236) | (380,794) |
| **ចំនួនចុះបញ្ជីសុទ្ធ** | **219,795** | **62,866** | **921** | **-** | **283,582** |
| ស្មើនិងពាន់រៀល | **903,797** | **258,503** | **3,791** | **-** | **1,166,091** |

# កំណត់សំគាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ( ត )

## ១៧. ផ្នែកទន់កុំព្យូទ័រ

| ថ្ងៃទី ១ មករា ២០០៤ | ផ្នែកទន់កុំព្យូទ័រ ដុល្លារអាមេរិក |
|---|---|
| តំលៃដើម | 323,105 |
| រំលស់បង្គរ | (61,262) |
| **ចំនួនចុះបញ្ជីសុទ្ធ** | **261,843** |
| **ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ធ្នូ ២០០៤** | |
| ចំនួនចុះបញ្ជីសុទ្ធដើមគ្រា | 261,843 |
| វិសមភាពនៃការប្តូរប្រាក់ | (3,317) |
| បូកបន្ថែម | 28,928 |
| រំលស់បន្ទុក | (40,410) |
| **តំលៃចុះបញ្ជីសុទ្ធចុងគ្រា** | **247,044** |
| **ថ្ងៃទី ៣១ ធ្នូ ២០០៤** | |
| តំលៃដើម | 347,941 |
| រំលស់បង្គរ | (100,896) |
| ចំនួនចុះបញ្ជីសុទ្ធ | 247,044 |
| **ស្មើនិងពាន់រៀល** | **994,848** |
| **ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ធ្នូ ២០០៥** | |
| ចំនួនចុះបញ្ជីសុទ្ធដើមគ្រា | 247,044 |
| វិសមភាពនៃការប្តូរប្រាក់ | (9,710) |
| បូកបន្ថែម | - |
| រំលស់បន្ទុក | (55,791) |
| ចំនួនចុះបញ្ជីសុទ្ធចុងគ្រា | 181,543 |
| **ថ្ងៃទី ៣១ ធ្នូ ២០០៥** | |
| តំលៃដើម | 340,749 |
| រំលស់បង្គរ | (159,206) |
| ចំនួនចុះបញ្ជីសុទ្ធ | 181,543 |
| **ស្មើនិងពាន់រៀល** | **746,505** |

ផ្នែកទន់កុំព្យូទ័រ គឺមានទាក់ទងនឹងប្រព័ន្ធកុំព្យូទ័រ Core Banking System ក្នុងឆ្នាំ ២០០៥ ធនាគារបានពិនិត្យមើលឡើងវិញនូវចំណាយរំលស់លើប្រព័ន្ធកុំព្យូទ័រនេះ ហើយបានសំរេចកាត់បន្ថយអាយុកាលប្រើប្រាស់របស់វា ពី១០ឆ្នាំ មក ៥ ឆ្នាំវិញ ដូចដែលបានគូសបង្ហាញនៅក្នុងកំណត់សំគាល់ ២.១០។ ការកែប្រែអាយុកាលរបស់ប្រព័ន្ធកុំព្យូទ័រនេះ ត្រូវបានគេទទួលស្គាល់ថាជាការផ្លាស់ប្តូរនៃគណនេយ្យប៉ាន់ស្មាន ហើយត្រូវបានគេអនុវត្តជាបន្តបន្ទាប់មក។ ជាលទ្ធផលនៃការកែប្រែនេះបានបណ្តាលអោយកើនឡើងនូវចំណាយរំលស់ចំនួនប្រហែល ១៥,៩៨០ដុល្លារ នៅក្នុងឆ្នាំ ២០០៥។

## ១៨. ទ្រព្យសកម្មផ្សេងៗ

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| សមតុល្យមូលប្បទានប័ត្របរទេស មូលប្បទានប័ត្រទេសចរណ៍ និងប័ណ្ណឥណទានធ្វើបេឡានិច្ច័យ | | | | |
| កំពុងបញ្ជូន | 763,161 | 2,867,945 | 3,138,120 | 11,549,215 |
| នៅក្នុងដៃ | 51,377 | 51,351 | 211,262 | 206,790 |
| ចំណូលការប្រាក់បង្គរ | 663,126 | 277,263 | 2,726,774 | 1,116,540 |
| បុរេប្រទាន | 158,090 | 103,757 | 650,065 | 417,828 |
| **សរុប** | **1,635,754** | **3,300,316** | **6,726,221** | **13,290,373** |
| សំវិធានធនសំរាប់ការប្រាក់បង្គរ ដែលទទួលបានពីឥណទាន | - | (83,272) | - | (335,336) |
| **សរុប** | **1,635,754** | **3,217,044** | **6,726,221** | **12,955,037** |

## ១៩. ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ប្រាក់បញ្ញើពីធនាគារនិវាសជន | 380,312 | 622,233 | 1,563,844 | 2,505,734 |
| ប្រាក់បញ្ញើពីធនាគារអនិវាសជន | 352,471 | 314,581 | 1,449,358 | 1,266,816 |
| **សរុប** | **732,783** | **936,814** | **3,013,202** | **3,772,550** |

ប្រាក់បញ្ញើទាំងនេះមិនមានចំណូលការប្រាក់ទេ

## ២០. ប្រាក់បញ្ញើអតិថិជន

### ក. ការវិភាគតាមប្រភេទប្រាក់បញ្ញើ

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ប្រាក់បញ្ញើចរន្ត | 46,585,993 | 44,148,505 | 191,561,604 | 177,786,028 |
| ប្រាក់បញ្ញើសន្សំ | 49,746,807 | 47,104,321 | 204,558,871 | 189,689,100 |
| ប្រាក់បញ្ញើមានកាលកំណត់ | 43,660,170 | 45,902,239 | 179,530,621 | 184,848,316 |
| ប្រាក់បញ្ញើធានា ( មើលកំណត់សំគាល់២៣) | 1,877,135 | 818,133 | 7,718,779 | 3,294,620 |
| គណនីប្រាក់បញ្ញើផ្សេងៗ | 1,025,371 | 1,294,026 | 4,216,321 | 5,211,048 |
| **សរុប** | **142,895,476** | **139,267,224** | **587,586,196** | **560,829,112** |

ប្រាក់បញ្ញើធានាតំណាងអោយសមតុល្យសរុបនៃប្រាក់បញ្ញើជាសាច់ប្រាក់ គ្មានការប្រាក់ដែលតំរូវពីអតិថិជន សំរាប់លិខិតឥណទាន និងលិខិតធានាដែលនៅមានសមតុល្យនាចុងការិយបរិច្ឆេទ ( មើលកំណត់សំគាល់ ២៣) ។

គណនីប្រាក់បញ្ញើផ្សេងៗ រួមមានប្រាក់បញ្ញើអតិថិជនបណ្តោះអាសន្ន និងមូលប្បទានប័ត្រសំរាប់ធានា ការផាត់ទាត់ដែលមានចំនួនស្មើ ៥៨០.០២៧ដុល្លារ និងចំនួន ២៥៤,០០៦ដុល្លារ ( ឆ្នាំ ២០០៤ មានចំនួន ៦៥៥.៧៦៣ដុល្លារ និងចំនួន ២៨៣.២០៣ដុល្លារ) តាមលំដាប់លំដោយ ។

### ខ. ការវិភាគតាមប្រភេទអតិថិជន

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ឯកត្តជន | 67,823,800 | 71,752,565 | 278,891,467 | 288,947,581 |
| ក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាល | 41,684,633 | 38,220,148 | 171,407,211 | 153,912,538 |
| ក្រុមហ៊ុនរដ្ឋ | 33,387,043 | 29,294,511 | 137,287,518 | 117,968,993 |
| **សរុប** | **142,895,476** | **139,267,224** | **587,586,196** | **560,829,112** |

** បានត្រួតពិនិត្យជាប្រាក់រៀល*

## កំណត់សំគាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ (ត)

| គ. ការវិភាគតាមស្ថានភាពនិវាសជន | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| និវាសជន | 140,594,649 | 135,865,686 | 578,125,196 | 547,131,117 |
| អនិវាសជន | 2,300,827 | 3,401,538 | 9,461,000 | 13,697,995 |
| **សរុប** | **142,895,476** | **139,267,224** | **587,586,196** | **560,829,112** |

| ឃ. ការវិភាគតាមទំនាក់ទំនង | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| ភាគីខាងក្រៅ | 142,712,595 | 138,928,406 | 586,834,189 | 559,464,690 |
| បុគ្គលិក | 182,881 | 338,818 | 752,007 | 1,364,422 |
| **សរុប** | **142,895,476** | **139,267,224** | **587,586,196** | **560,829,112** |

| ង. អត្រាការប្រាក់ | | 2005 | 2004 |
|---|---|---|---|
| គណនីចរន្ត | | 0% | 0% |
| ប្រាក់បញ្ញើសន្សំ | ជាដុល្លារ | 0.75% -1.5% | 0.75% -1.5% |
| | ជារៀល | 1.5% - 2% | 1.5% - 2% |
| ប្រាក់បញ្ញើមានកាលកំណត់ជាដុល្លារអាមេរិក: | ១ ខែ | 1% - 2% | 1% - 2% |
| | ៣ ខែ | 3% | 3% |
| | ៦ ខែ | 4% - 4.5% | 4% - 4.5% |
| | ១២ ខែ | 5% - 5.5% | 5% - 5.5% |
| ប្រាក់បញ្ញើមានកាលកំណត់ជារៀល: | ៣ ខែ | 4.5% | 4.5% |
| | ៦ ខែ | 5.5% | 5.5% |
| | ១២ ខែ | 6.5% | 6.5% |

## ២១. ទ្រព្យអកម្មផ្សេងៗ

| | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| បង្គរការប្រាក់ត្រូវសង | 652,685 | 627,214 | 2,683,841 | 2,525,791 |
| ពន្ធពន្យារផ្នែកទ្រព្យអកម្ម (មើលកំណត់សំគាល់ ១០) | 33,420 | 55,780 | 137,425 | 224,627 |
| ទ្រព្យអកម្មជាមូលនិធិសោធនិវត្តន៍ | 176,692 | 133,684 | 726,557 | 538,347 |
| សារពើពន្ធកាត់ទុក | 61,342 | 64,871 | 252,239 | 261,237 |
| បង្គរកំរៃឈ្នួលរបស់ធនាគារកណ្តាលជាការ ផ្ទេរភាគហ៊ុន | 59,582 | - | 245,000 | - |
| ទ្រព្យអកម្មផ្សេងៗ | 39,386 | 66,538 | 161,957 | 267,951 |
| **សរុប** | **1,023,107** | **948,087** | **4,207,019** | **3,817,953** |

| សេចក្តីលំអិតនៃចលនទ្រព្យអកម្មមូលនិធិសោធនិវត្តន៍នេះ មានដូចខាងក្រោម : | 2005 ដុល្លារអាមេរិក | 2004 ដុល្លារអាមេរិក* | 2005 ពាន់រៀល | 2004 ពាន់រៀល |
|---|---|---|---|---|
| សមតុល្យនាថ្ងៃទី ១ មករា | 133,684 | 84,058 | 538,347 | 338,503 |
| វិសមភាពនៃការប្តូរប្រាក់ | (2,763) | - | - | - |
| បូកបន្ថែមក្នុងឆ្នាំ: | | | | |
| ការផ្តល់ដោយបុគ្គលិក ៥% | 17,934 | 16,515 | 73,743 | 66,504 |
| ការផ្តល់ដោយធនាគារ ៥% | 17,934 | 16,515 | 73,743 | 66,504 |
| ការប្រាក់ (កំណត់សំគាល់ ៤) | 18,530 | 19,945 | 76,194 | 80,317 |
| ការផ្តល់ប្រាក់ចូលនិវត្តន៍ទៅអោយបុគ្គលិក | (8,627) | (3,349) | (35,470) | (13,481) |
| **សមតុល្យថ្ងៃទី ៣១ ធ្នូ** | **176,692** | **133,684** | **726,557** | **538,347** |

** បានត្រួតពិនិត្យជាប្រាក់រៀល*

## ២២. ដើមទុននិងទុនបំរុង

### ដើមទុន

ចំនួនសរុបភាគហ៊ុនទាំងអស់មានចំនួន ៥០,០០០ លានរៀល ដោយមានតំលៃ ១០០ ពាន់រៀលក្នុងមួយភាគហ៊ុន។ ការបញ្ចេញភាគហ៊ុនទាំងអស់គឺជាភាគហ៊ុនធម្មតា ដែលត្រូវបានបង់យ៉ាងពេញលេញ។

| | 2005 % ម្ចាស់ភាគហ៊ុន | 2005 គិតជាពាន់រៀល | 2004 % ម្ចាស់ភាគហ៊ុន | 2004 គិតជាពាន់រៀល |
|---|---|---|---|---|
| សេចក្តីលំអិតនៃភាគហ៊ុន នៅថ្ងៃទី ៣១ ធ្នូ ២០០៥ មានដូចតទៅ: | | | | |
| ធនាគារកាណាឌីយ៉ា | 46% | 23,000,000 | - | - |
| ING Holding Company Ltd. | 44% | 22,000,000 | - | - |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 10% | 5,000,000 | 80% | 40,000,000 |
| ធនាគារកណ្តាល | - | - | 20% | 10,000,000 |
